
ទស្សនាវដ្ដី
លេខ ៧
ពុទ្ធិកវិទ្យាល័យ
ទីចាត់ការ វត្តលង្កា សង្កាត់លេខ៦
ភ្នំពេញ
ចងក្រង.

Don Offert par M.
IMPRIMERIE VIRIYA PPENH

# វិចារណកថា

## មហាភិបូជា (ក្នុងឱកាសបុណ្យពុទ្ធជយន្តី ២៤.៥.៥៦)

១– អទ្ធតិយេ សហស្សម្ហិ វេសាខេ បុណ្ណមេ ទិតេ
ពុទ្ធស្ស បរិនិព្វានា បត្តេ សំវច្ឆរេ វរេ ។

២– នានា ជនា សមាគម្ម ពោធិមណ្ឌេ សុមណ្ឌិតេ
មហុស្សវំ បវត្តេសុំ ទស្សេន្តា ពុទ្ធគារវំ ។

៣– បញ្ចសីលំ សមាទិសុ ភាវេសុំ មេត្តភាវនំ



ក្នុងពិធីបុណ្យកតញ្ញូកតវេទី សម្តេចបានទទួលការថ្វាយពរជ័យពីសំណាក់ព្រះថេរានុថេរៈគ្រប់ឋានៈ

មោចនត្ថាយ សង្គាមំ បត្តេសុំ ទេហមានសំ ។

៤– ពោធិយា អង្គណំ សត្តំ ចីវរេន វិភេចយិ
សមុទ្ទគុណតាយន្តា បក្កមីសុ ជិនត្រជា ។

៥– អដ្ឋង្គសីលសម្បន្នា ឧបាសក-ឧបាសិកា
និសិន្នា ពោធិឆាយាយ ភាវេសុំ ពុទ្ធភាវនំ ។

៦– អាគតោ តត្ថ នាហោសិ ពោធិយ អង្គណេ ជន
ឆទ្ទំ វិយ អដ្ឋំសុ ឆព្ពណ្ណធជបន្តិយោ ។

៧– អបេតុបាហនា តត្ថ នានាភូសនភូសិតា
ចរិំសុ ពោធិសាមន្តេ និនន្ទី ទេវ-អច្ឆរា ។

## ទិវា សុទ្ធបូជា-បរិហារោ

៨– យត្ថត្ថ មហាពោធិ ធម្មសាលា សុការិតា
ពោធិយា អវិទូរស្មឹ ធម្មបាលេន ធីមតា ។

៩– តតោ បត្វា មហាបូជា បរិហារេហិ និក្ខមិ
សាធុការេ ច និន្នាទោ សង្ខនាទោ ច វត្តយិ ។

១០– នានា តុរិយគណ្ឋានិ វាទេន្តិ តិព្វតា យតី
វិចិត្តធជធារេន្តា និក្ខមន្តិ បុរេតរំ ។

១១– បុប្ផរាសឹ គហេត្វាន សីហឡា ភិក្ខវោ ជន
តថេវ ស្យាម-ភិក្ខូ ច គច្ឆន្តិ យុគទស្សិនោ ។

១២– កម្ពុជទេស-ភិក្ខូ ច អថោបិ ច មរម្មកា

| | |
|---|---|
| ឥណ្ឌបិនាគតា ភិក្ខូ | តថេវ បិនទេសិកា ។ |
| ១៣– អសាមទេសវាសី ច | បិតាគុំ-ទេសា សមាគតា |
| នេបាលទេសវាសី ច | ភិក្ខូ ការតវាសិកា ។ |
| ១៤– កាសាវធារី តេ សព្វេ | យតយោ ពុទ្ធសាវកា |
| ពុទ្ធស្ស បរិនិព្វានំ | សំវេគាវ សរន្តិ ច ។ |
| ១៥– នានា ទេសទិសាយត្តា | នរនារីគណា តតោ |
| សទ្ធា សំវេគពហុលា | អនុគច្ឆន្តិ ភិក្ខវោ ។ |
| ១៦– ឆព្វណ្ណំ សិនិទ្ធំ | ធជំ ធារេន្តិ សោភតា |
| នេន្តិ បុណ្ណឃដានិ ច | មរម្មនិតា កិរ ។ |
| ១៧– ខុជន្តំ រសវន្តំ | សុគន្ធំ វរភោជនំ |
| ឧត្តមង្គេន ធារេន្តិ | ឯកច្ចេ សីលវន្តិយោ ។ |
| ១៨– គហេត្វា ខជ្ជភោជ្ជានិ | ផលបណ្ណកានិ ច |
| សុគន្ធំ សុរភិ ចេវ | វិម្ហយប្បត្តមានសា ។ |
| ១៩– បទក្ខិណំ ករិត្វាន | តិក្ខត្តុំ ពោធិបាទបំ |
| បូជយិត្វាន តំ សព្វេ | ធមាយំ ហិ និសីទិយ ។ |
| ២០– គោធី បមុត្តិ ឯកច្ចេ | សីរសា និបតន្តិ ច |
| អាសិញ្ចិត្វាន ឧទកំ | បុប្ផំ អវកិរន្តិ ច; |
| កតញ្ជលី នមស្សន្តិ | អស្សុបុណ្ណមុខា តទា ។ |
| ២១– «នមោ តស្ស មុនិន្ទស្ស | នមោ ធម្មស្ស តស្ស ច |

សង្ឃស្សបិ នមោតស្ស    តេសំ គុណំ នមោ នមោ ៗ

២២– នានា ភាសាហិ ភាសន្តា    នានា ទេសា សមាគតា

បាលិភាសាយ តេ សព្វេ    អភិវន្ទន្តិ គោតមំ ។

---

# ដំណឹងសាសនា

## បុណ្យកតញ្ញូកតវេទី

## បំពោះសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សាគណមហានិកាយ

ព្រះមហា សម-សុខ សុមនោ

អាចារ្យសាលាពុទ្ធិកបឋមសិក្សាវត្តលង្កា ភ្នំពេញ

រៀបរៀង

ដោយសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា មានព្រះជន្មវស្សាខិតសសៀចូលទៅក្នុងបច្ឆិមវ័យណាស់ហើយ ទាំងមានព្រះអាពាធប្រចាំនៅក្នុងករជកាយទឹងតឹងតែងក្នុងកាព្យាលកំបាត់ជាពន់ពេកទៀត, គណៈធម្មការវត្តលង្កា ទាំងព្រះសង្ឃទាំងគ្រហស្ថ មានព្រះតេជព្រះគុណព្រះញាណកោសល ញាណ-ឈឹន, ព្រះពុទ្ធវង្ស កៅ-ស៊ឹម និងលោកប្រធាន ម៉ុម-យ៉ែមជាដើម ព្រមទាំងក្រុមអាចារ្យសម្រាប់វត្ត មានលោកឧកញ៉ាឧត្តមសិក្ខាចារ្យកែម-អ៊ុលជាប្រធាន បានបាត់ការប្រជុំពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៥៦




ពិធីដាក់បាតចំរើនព្រះជន្មសម្តេច

ដើម្បីប្រឹក្សាគ្នាអំពីការធ្វើបុណ្យកតញ្ញូកតវេទីប្រគេនចំពោះសម្តេច ជាកិច្ចនៃបដិការគុណ ៗ ក្នុងអង្គប្រជុំ, គណៈកម្មការទាំងអស់បានមូលមតិគ្នាជាឯកច្ឆ័នថា នឹងធ្វើបុណ្យនោះនៅថ្ងៃសៅរ៍-អាទិត្យ ២-៣កើត ខែបឋមាសាឍ ឆ្នាំវកអដ្ឋស័ក ព. ស. ២៤៩៩ ត្រូវនឹងថ្ងៃទី៩-១០ ខែមិថុនា ឆ្នាំ១៩៥៦ ព្រមទាំងបានរៀបចំគណៈកម្មការ សម្រាប់ត្រួតត្រាចាត់ការធ្វើបុណ្យជា៤សង្កាត់គឺ

១–ព្រះសង្ឃជាមេក្រុមទាំង៨, ២–ព្រះសង្ឃដែលមានសមត្ថភាព, ៣–គណៈកម្មការវត្ត, ៤ក្រុមអាចារ្យសម្រាប់វត្ត ៗ

ថ្ងៃទី១នៃកាលបរិច្ចេទបុណ្យ

ថ្ងៃសៅរ៍ទី៩ ខែមិថុនា ឆ្នាំ១៩៥៦, មេឃមីស្រទំអាប់អួរដោយផ្ទាំងពពកដែលពព្វូន
គ្នាខាន់ខាប់កកជាប្រទាប់ជាដុំ បម្រុងនឹងបង្អុរភ្លៀងឲ្យធ្លាក់ចុះមកស្រោចស្រប់ទេសភាព
នឹងធម្មជាតិទាំងស្រុង តែពុំបានបង្អុរចុះវិញ ព្រោះត្រូវដំនោរព្រះពាយបក់បោកបន្សាត់
ឲ្យឃ្លាតទៅឆ្ងាយជាលំដាប់ ៗ ពេលបន្ទាប់នោះអាកាសក៏វាលល្ហរល្ហៅស្អាតស្រឡះ
ប្រាសចាកនភោធូមទាំងអស់, រស្មីដ៏ស្រទន់នៃព្រះទិនករបានចុះបញ្ចាំងមកលើពិភព
លោកទាំងមូល, នៅវត្តលង្កា សង្កាត់លេខ៦ ក្រុងភ្នំពេញ គេបានឃើញផ្ទៃអាវាស
ទាំងមូលស្អាតស្អំបរិសុទ្ធល្អ ហើយនៅក្លោងទ្វារវត្តឃើញមានដោតទង់សាសនា៣ជាលំ
អរ ដែលត្រូវខ្យល់បក់មកម្តងៗ ហាក់ដូចជាជួយអបអរសាទរយ៉ាងមហិមា គឺជានិមិត្តរូបនៃ
បុណ្យតាមប្រពៃណីព្រះពុទ្ធសាសនាផងៗ ក្បែរក្លោងទ្វារធំខាងក្នុងវត្ត ក្រោមម្លប់ដើមជ្រៃ
ក្រឹមដ៏ត្រឈៃ មានក្តារខៀនបញ្ឈរមួយ ដែលគេបានទាក់ជាអក្សរធំៗនៅលើនោះថា:

## បុណ្យកតញ្ញូកតវេទី

ចំពោះសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្ស

បញ្ឈរបែរទៅខាងជើង ជាសញ្ញាដល់គមនាគមន៍ទូទៅ ៗ ខាងកើតហោត្រៃ
ផ្លាល់ មានការិយាល័យ ២ សម្រាប់ទទួលបច្ច័យដែលអស់លោកជាពុទ្ធសាសនិកជន
បានបូជា ជាជំនួយដល់ការទិញឧសថមកព្យាបាលព្រះរោគសម្តេច ៗ នៅលើធម្មកុដិ
ក្បែរអាសនៈសម្តេច មានរៀបចំក្រាលអាសនៈដ៏ស្អាតបាតសម្រាប់ព្រះសង្ឃសមណ
ស័ក្តិដែលបាននិមន្តមកក្នុងពិធីបុណ្យនោះ ព្រមទាំងមានតាក់តែងរបនាចង់រយោលផ្កា
ជាច្រើន នៅចំខាងមុខបុស្បុកបល្ល័ង្កដែលដំកល់ព្រះពុទ្ធរូប ' ព្រះបរមសារីរិកធាតុ,
ព្រះអរហន្តធាតុ នឹងគ្រឿងភ្ញីផ្កាសក្ការបូជា ៗ នៅខាងក្រៅវិហារ, គ្រប់ទ្វារ មាន

គាត់តែងដោយបំពង់អគ្គិសនីវែង ៗ និងចងបំពង់ធម្មតាភាយជុំវិញទៅតាមលំដាប់ក្បាច់ពេជ្រផង ៗ ឯខាងក្នុងវិញ គេបានរៀបចំតុសក្ការៈមួយដ៏ធំនៅចំព្រះភក្ត្រនៃព្រះពុទ្ធបដិមាករសម្រាប់ថ្វាយភ្ញាសក្ការៈ ៗ នៅលើតុតាំងនោះមានក្រាលព្រំដាលំអ សម្រាប់ដំកល់របស់បុរាណវត្ថុជាច្រើនដូចជាទានបញ្ចរគ្គជាដើម ដាក់ឆ្លាស់គ្នាលាយចម្រុះដោយបុប្ផាវិកតិ នីងៈលេចដោយរស្មីដ៏ស្រអែតនៃបំពង់ពណ៌អគ្គិសនីដែលបានបើកបំភ្លឺក្នុងពេលងងឹត , នៅលើតុដដែលនោះ គេបានដំកល់ព្រះពុទ្ធរូបមួយព្រះអង្គតូច គង់ប្រថាប់ក្រោមស្លឹកដ៏សាខានៃពោធិព្រឹក្ស នាំឲ្យយើងនឹកដល់កាលដែលទ្រង់ទើបនឹងបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ នឹងផ្ចាញ់មារព្រមទាំងសេនាឲ្យខ្ចាយខ្ចាបដោយសារព្រះបារមីធម៌ ដែលក្នុងពេលនោះទ្រង់ប្រថាប់ក្រោមម្លប់នៃព្រះពោធិព្រឹក្សដែរ , ជាពិសេសគេបានរចនាផ្កាឈូកក្រពុំមួយយ៉ាងធំកំពស់មួយម៉ែត្រម្ភៃ ពីឈើគគីរនឹងឬស្សី ចងតាក់តែងដោយបំពង់អគ្គិសនីតូច ៗ ហូរហែរាយតាមលំដាប់គ្រប់កន្លាស់ពណ៌ខៀវ . លឿងក្រហម - ស ល្អត្រកាល ហើយនៅចំកណ្ដាល បានដំកល់កោដ្ឋព្រះអដ្ឋិនៃព្រះអរហន្តមួយព្រះអង្គ ដែលមាននាមនឹងគោត្តមិនប្រាកដ ដំកល់នៅលើតុនោះដែរ ៗ

ព្រះអាទិត្យទន់ទាបទៅតាមសភាពធម្មតា , បរិស័ទទាំងឡាយជាសិស្សគណខ្លះជាឧបាសកឧបាសិកាដើងវត្តខ្លះ ជាញាតិមិត្តធ្លាប់មានការគោរពនឹងស្រឡាញ់ចំពោះគុណធម៌របស់សម្ដេចខ្លះ បានអញ្ជើញមកជាបន្ទាប់ ៗ គ្នាដោយមានទឹកមុខក្រៀមក្រំនឹងរន្ធត់ចិត្តជាពន់ពេក ចំពោះអាការភេទរបស់សម្ដេច ៗ ដល់ពេលព្រលប់ក្ខាម គួរឲ្យយល់ថានឹងមានងងឹតអន្ធការដ៏ធំបំផុលមកគ្របដណ្ដប់ផ្ទៃវត្តជាពុំខាន ព្រោះថ្ងៃនោះអាកាសអាប់អួរអោរទឹមហាក់ដូចជាបម្រុងតែនឹងបង្អុរភ្លៀងចុះ តែដោយអំណាចភ្លើងអគ្គិសនីរាយតាម

វិថីបូលមកកាន់វិហារនឹងតាមលំដាប់ក្នុងពិធីក៏បានបញ្ចេញឥទ្ធិពលកំចាត់ងងឹតនោះ ហើយបញ្ចេញរស្មីដ៏ភ្លឺត្រចះផ្ទះមកលើក្រុមអ្នកទាំងពួង ។ ម៉ោង ១៩ ដោយមានស្គររគាំងជាសញ្ញា , ភិក្ខុសង្ឃក្នុងវត្តទាំងអស់បាននិមន្តឡើងទៅលើធម្មកុដិធ្វើកិច្ចវត្តចំពោះសម្តេចដើម្បីសំដែងការរីករាយនឹងស្វាមីភក្តិដោយសុទ្ធចិត្តរៀង ៗ ខ្លួន ៗ សម្តេចបានប្រទានឱវាទដោយសំឡេងទទេគ្រួសនសព្វថាខ្ញុំមានអំណរណាស់ ដោយឃើញលោកទាំងអស់រួបរួមធ្វើបុណ្យជាកិច្ចតបឧបការគុណដល់ខ្ញុំដែលជាគ្រូឧបាធ្យាយ,សូមឲ្យលោកទាំងអស់គ្នារក្សាអប្បមាទធម៌រក្សាសាមគ្គីធម៌ ដើម្បីនឹងថែទាំសាសនាឲ្យបានរុងរឿងទៅអនាគត ”។

ម៉ោង ២០ ព្រះមហាថេរទាំងឡាយគឺ សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកវត្តឧណ្ណាលោម, ព្រះតេជព្រះគុណព្រះពោធិវង្សហួត-តាត ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត នឹងជាអធិបតីក្រុមជំនុំព្រះត្រៃបិដក, ព្រះសុធម្មាធិបតីកុល-ទេស ស្តីទីសង្ឃនាយកវត្តបទុមវតី, ព្រះមុនីកោសលសោម-ឈុន អធិបតីរងក្រុមជំនុំព្រះត្រៃបិដកនឹងជាមេគណខេត្តកណ្តាល, ព្រះឃោសធម្មមុំង-សែស ចៅអធិការវត្តមហាមន្ត្រី, ព្រះអរិយកស្សបកែវ-អ៊ួច វត្តបទុមវតី, ព្រះសិរីសុគន្ធមុនី អន-ឡាប ចៅអធិការវត្តកោះ, ព្រះវិន័យធម្មអ៊ឹម-ចិត វត្តមហាមន្ត្រី, ព្រះវិន័យធរ ឯក-ញឹម វត្តពិកទូវង្ស នឹងដំណាងព្រះធម្មឃោសាចារ្យ ចៅអធិការវត្តសារាវ័ន បាននិមន្តមកដល់ជាលំដាប់ ហើយនិមន្តឡើងទៅលើធម្មកុដិធ្វើការវិកិច្ចសាកសួរអាពាធសម្តេចព្រះធម្មលិខិត ដែលមានព្រះតេជព្រះគុណព្រះញាណកោសល ញាណ-ឈឹន, ព្រះពុទ្ធវង្សកៅ-ស៊ឹម, ព្រះបវរ-សត្ថា ពេជ្រ-តុល នឹងព្រះសង្ឃឯទៀតគង់អមផង ៗ ឯផ្នែកគ្រហស្ថ, យើងបានសង្កេតឃើញលោកយិន-ឆៃ ចាងហ្វាងអនុវិទ្យាល័យកម្ពុជបុត្រ, លោកវ៉ាយ-ប៊ុក ក្រុម

ការនៅពុទ្ធសាសនបណ្ឌិត្យ និងជាអធិបតីសមាគមមិត្តពុទ្ធិកវិទ្យាល័យ, លោកអេង-ស៊ុទ្ធ ព្រះរាជ្ញាសាលាលុយឃុនក្រុងភ្នំពេញ, លោកអ៊ូ-គង់, មាស-ម៉ន, ពុត-អ៊ុំ អតីតក្រុមប្រឹក្សាព្រះរាជអាណាចក្រ, លោកជ័យ-មៀច, ហ្វុនឧត្តមប្រឹក្សា ចាប-ពិន នាយការិយាល័យក្រុមជំនុំទំនៀមទំលាប់ខ្មែរ និងអស់លោកឯទៀតជាច្រើនដែលយើងសូមអភ័យទោស ដោយពុំបានរាប់នាមឲ្យសព្វគ្រប់ ។ បន្ទាប់ពីការជួបជុំបន្តិចមក, ព្រះញាណកោសលមានថេរដីកាអញ្ជើញលោកឈឹម-ស៊ុំ សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ជំណាងសិស្សានុសិស្សឲ្យថ្លែងសុន្ទរកថាមួយរៀបរាប់ពីបុព្វហេតុបុណ្យនិងព្រះកិត្តិគុណរបស់សម្ដេចព្រះធម្មលិខិត ក្នុងកណ្ដាលទីប្រជុំលើធម្មាសន៍ ។ (នៅមានត)

---

ប្រែចាកកាសែត ហិណ្ឌូស្ថាន តៃមស៍ ដោយភិក្ខុ ឃោសានន្ទ កែសម្រួលដោយភិក្ខុវីបណ្ឌិត និស្សិតមហាវិទ្យាល័យនាលន្ទា ប្រទេសឥណ្ឌា ។

## សុន្ទរកថា
## របស់លោកប្រធានាធិបតី អនុប្រធានាធិបតី និងនាយករដ្ឋមន្ត្រី
## ប្រទេសឥណ្ឌា ។

លោកប្រធានាធិបតី លោកអនុប្រធានាធិបតី និងលោកនាយករដ្ឋមន្ត្រីនៃប្រទេសឥណ្ឌា បានសំដែងសុន្ទរកថាក្នុងឱកាសបុណ្យពុទ្ធជយន្តី ដើម្បីញាំងជនរួមជាតិរបស់លោកឲ្យប្រតិបត្តិតាមពុទ្ធោវាទ សម្រាប់ជីវភាពរាល់ថ្ងៃនៅខាងក្នុងប្រទេសនិងខាងក្រៅប្រទេសទាំងឡាយទូទៅ ។

សុន្ទរកថានេះ ដែលអាចទ្រទ្រង់នូវឧត្តមគតិរបស់ពុទ្ធជនទាំងឡាយក្នុងពិភព

លោក ប្រធានាធិបតីនិងលោកនាយករដ្ឋមន្ត្រី នៃសហភាពភូមា, លោកនាយករដ្ឋមន្ត្រីប្រទេសកម្ពុជា, លង្កា, ជប៉ុន, ចិន, លាវ, ថៃយ៍និងនេប៉ាល់ ទទួលរាប់រងអនុមោទនាដោយសោមនស្សចេតនា ។

ក្នុងឱកាសនោះ ទីលានរាមលីលា ដេល្ហី ដ៏ធំដោរពោរពេញដោយមនុស្សជាតិគ្រប់សាសន៍ គ្រប់ភាសា ។ ក្លោងទ្វារធំកណ្ដាលមានរូបចំឡាក់ពុទ្ធប្រវត្តិ មានចារឹកពុទ្ធវចនផ្សេង ៗ ព្រមទាំងមានបដាមួយចារឹកជាអក្សរទេវនាគរីថា: «ពុទ្ធំ សរណំ គច្ឆាមិ» ។

កម្មវិធីបានតាំងផ្ដើមឡើងដោយភ្លេងនិងចំរៀងលន្លង់លន្លោច ដែលមហាបណ្ឌិតកវីឈ្មោះតាគ័របាននិពន្ធពុទ្ធប្រវត្តិ ហើយបានឲ្យឈ្មោះថា: «ហិង្សាយុគមគ្គប្រថវី»; ភ្លេងនេះលេងដោយក្រុមសិល្បស្ថានីយវិទ្យុដេល្ហីនិងកាល់កត្តា ។ បន្ទាប់មកលោកបណ្ឌិត ម៉ៃថិឡី-សារ័ន-គុប្ត បានសូត្រកាព្យនិពន្ធយ៉ាងពិរោះក្បោះក្បាយ ដែលលោកបានតែងឡើងសម្រាប់ឱកាសនោះ ។



ទិដ្ឋភាពនៃព្រះស្តូប និងពោធិព្រឹក្សពេលមុនពិធីបុណ្យ ។ ទីវាលខាងក្រោយព្រះស្តូប មានបណ្ដោយប្រមាណ ២៥០ម ទទឹង ១០០ម ទើបពង្រាបហើយថ្មី ។

លោកបណ្ឌិតរាជេន្ទ្រប្រាសាទ ប្រធានាធិបតីប្រទេសឥណ្ឌា បានថ្លែងសុន្ទរកថា

ដោយសង្ខេបថា៖ «លោកមានសេចក្ដីសង្ឃឹមយ៉ាងមាំថា នានាប្រទេសសាកលលោកបានប្រមូលកម្លាំងគ្នាតែងតាំងកម្មវិធីមួយសម្រាប់ការបន្ថយអាវុធ; ការនេះមុខជាបានផលល្អមិនខាន» ។ រួចលោកមានប្រសាសន៍តទៅទៀតថា៖ «យើងទាំងឡាយគប្បីជឿជាក់ថា ពិភពលោកទាំងមូលមុខជាអើពើ អើតក ងើបមុខសំឡឹងរកព្រះពុទ្ធសាសនាទីង

រាជបេសកម្មរបស់ព្រះមហាចក្រ-ពត្រាធិរាជ ព្រះនាមធម្មាសោក មិនខាន; យើងទាំងឡាយគប្បីប្រតិបត្តិតាម ពុទ្ធោវាទមួយកន្លែងដូចតទៅនេះ «មានតែអហិង្សា គឺការមិនបៀតបៀនមិនគ្រប់សត្វតិចមិនរើសជាន់ឬសេចក្ដីមេត្តាករុណាប៉ុណ្ណោះឯង ទើបអាចរម្ងាប់បង់នូវភ្លើងហិង្សា គឺការរំលោភពានពារបាន» ។



គង្វាយព្រះដែលឧបាសក-ឧបាសិកាបានដង្ហែរយកមកថ្វាយ, គេបានប្រគេនមកព្រះសង្ឃ ហើយព្រះសង្ឃយកមកដាក់លើរតនបល្ល័ង្ក ។

គ្រហស្ថដែលនៅកកកុញពីខាងក្រោយកំពុងតែប្រគេនគ្រឿងសក្ការបូជាបន្តមកព្រះសង្ឃ

លោកបណ្ឌិតនេហរូនាយករដ្ឋមន្ត្រីប្រទេសឥណ្ឌា បានថ្លែងសុន្ទរកថាដោយសង្ខេបថា៖

«ប្រទេសឥណ្ឌានឹងនានាប្រទេសក្នុងសាកលលោកគួរគប្បីដើរតាមមាគ៌ា ដែលព្រះមហាបុរសឈ្មោះគោតមបានត្រាយទុកឲ្យ; គ្រាប់បែកបរមាណូមិនដែលស្ងប់ដោយគ្រាប់បែកបរមាណូឡើយ; ហេតុនេះគួរយើងទាំងឡាយសមាទានយកនូវឧត្ដមគតិ

៥ប្រការដែលឥណ្ឌា បានតែងតាំងឡើងសម្រាប់អន្តរជាតិ យកលំនាំតាមបញ្ញាសីលរបស់ព្រះពុទ្ធសាសនា„ ។

តមកទៀត លោកនេហរូ បានអំពាវនាវប្រជាករឲ្យក្រេបជញ្ជក់ នូវពុទ្ធធម្មរសដែលបំភ្លឺរដោយវិទ្យាសាស្រ្តទាន់សម័យ, ហើយមិនគប្បីជឿតាមគម្ពីររបស់លទ្ធិដែលមានសទ្ធាងងឹតងងល់ឡើយ ។ យើងត្រូវចាំជាក់ថា ព្រះសម្មាសម្ពុទ្ធបានបដិសេធចោល នូវការប្រកាន់វណ្ណៈអស់កាល ២.៥០០ ឆ្នាំមកហើយ តែការប្រកាន់វណ្ណៈនេះនៅរស់រវើក រហូតមកដល់សព្វថ្ងៃនេះ ។ ប្រទេសឥណ្ឌាគប្បីមានតែវណ្ណៈមួយ គឺជនជាតិឥណ្ឌាឯសាកលលោកក៏គប្បីមានតែវណ្ណៈមួយដែរ គឺមនុស្សជាតិទូទៅ ។



ពេលហែរប្រទក្សិណ ពួកនារីជាតិភូមាជាច្រើនទូលក្អមទឹកដែលមានដោតស្លឹកព្រីងពីលើជាសញ្ញានៃជម្ពូទ្វីប ។ ទឹកក្អមដែលអប់ក្រអូបឈ្ងុយឈ្ងប់ទាំងនោះគេយកទៅស្រោចគល់ពោធិព្រឹក្ស

លោកអនុប្រធានាធិបតិ ដុកទ័ររ៉ាធក្រិស្ណ៍ន បានសំដែងសុន្ទរកថាដោយសង្ខេបថា: «ប្រជាជាតិទាំងឡាយនឹងត្រឡប់ទៅជាមហាអំណាចបាន មិនមែនដោយមានមហាបុរសមកកើតទេ, ក៏ប៉ុន្តែលុះណាតែ ប្រជាជនព្រមព្រៀងគ្នាទាំងអស់ប្រតិបត្តិតាមគតិរបស់មហាបុរស ទើបប្រជាជាតិនោះៗ ត្រឡប់ទៅជាមហាអំណាចបាន ។

បើប្រសិនណាប្រជាករឥណ្ឌា មានប្រាថ្នានឹងឲ្យប្រទេសឥណ្ឌា ត្រឡប់ទៅជាមហាអំណាច ប្រជាករនេះត្រូវដើរតាមអដ្ឋង្គិកមគ្គ ដែលព្រះអរហំសម្ពុទ្ធបានត្រាយទុកឲ្យ ។ ២.៥០០ ឆ្នាំកន្លងមកហើយ ព្រះពុទ្ធជាម្ចាស់បានប្រកាសលុបលាងនូវវណ្ណៈ ហើយនិង ការសម្លាប់សត្វបូជាយញ្ញ, តែហាក់ដូចជាពុទ្ធប្រកាសនេះ មិនទាន់បានសម្រេចផលចប់ស្រេចនៅឡើយ ។ យើងជឿជាក់ថាប្រទេសឥណ្ឌា កំពុងតែចំរើនដុះដាលឡើង តាមលំអានមាគ៌ាដ៏បរិសុទ្ធរបស់ព្រះបរមគ្រូ ។ ប្រទេសឥណ្ឌា កំពុងកសាងជីវភាពថ្មីខាងក្នុងប្រទេស ព្រមទាំងបានស្ថាប័ននូវបញ្ចសីល ដែលជាឧត្តមគតិដ៏បវរសម្រាប់អន្តរជាតិ ” ។



លោកសង្ឃមហាយាន ( ទីបេត៍ ) កាន់ទង់នឹងក្លស់ដើរមុខគេៗ លោកពីរអង្គដើរមុខគេនោះ កំពុងផ្លុំសាំង, បន្ទាប់ពីពួកកាន់ទង់មានអ្នកផ្លុំត្រែវាយស្គរនឹងឆាប

## បុណ្យរំលឹកព្រះពុទ្ធសាសនាគំរប់២៥០០ព្រះវស្សានៃប្រទេសកម្ពុជា

ស្រង់ចេញពីសារពត៌មានកម្ពុជា (លេខ ៣១៩០)

ពួកពុទ្ធសាសនិកដែលបានរស់នៅទាន់ពេលបុណ្យរំលឹកព.ស.២៥០០ព្រះវស្សានៃព្រះសម្មាសម្ពុទ្ធសុទ្ធតែមានភ័ព្វសំណាងយ៉ាងត្រកាលក្រៃលែង ក្នុងចំណោមប្រទេស

ដែលកាន់ព្រះពុទ្ធសាសនានៅអាស៊ីទ្វីប, ប្រទេសកម្ពុជាបាននាមថាជាប្រទេសមួយមានព្រះពុទ្ធសនោវាទរុងរឿងជាចម្បង ។ ប្រជាពលរដ្ឋនៃប្រទេសនេះមានសទ្ធាមុតមាំណាស់ចំពោះព្រះពុទ្ធសាសនា ។

ជនជាតិខ្មែរទោះបីក្រីក្រភោគសម្បត្តិយ៉ាងណាក៏ដោយ តែងតែខិតខំបួរនឹងបុណ្យ រកជាតិសាសន៍ដទៃមកធៀបស្មើពិបាកណាស់; ត្រង់ណោះព្រោះគេជឿជាក់ថា ធ្វើបុណ្យបរិសុទ្ធចិត្ត ហើយធ្វើបាបបានក្តៅក្រហាយ ។ មួយទៀតគេជឿជាពិសេសថា ព្រះសមណៈគោត្តមបរមគ្រូ គឺព្រះអង្គជាសាស្តាឯក, ព្រះអង្គមានពុទ្ធប្រាជ្ញារកសាស្តាណាត្រឹមស្មើពុំបានឡើយ ។



ជាពិសេស ពួកភូមាបានយកក្មេងឆាបុំដែលមាននារីតូចៗ រាំដ៏ទន់ភ្លន់ទៅហែរប្រទក្សិណដែរ ។

ប្រជាជនខ្មែរផ្តោតចិត្តដោយស្មោះស្ម័គ្រចំពោះព្រះសម្ពុទ្ធអង្គនេះ រកអ្វីប្រៀបពុំបានទេ ហើយគេមានគំនិតបំណងមួយយ៉ាងមាំទៀតថា កាលបើធ្វើតាមព្រះបរមពុទ្ធោវាទនោះហើយ គេនឹងបានជួបសន្តិវរបទ "ផ្លូវស្ងប់យ៉ាងប្រសើរ", គោលគឺព្រះនិព្វានៗ សព្វថ្ងៃនេះជនជាតិកម្ពុជា, ដោយមានសទ្ធាយ៉ាងមាំចំពោះព្រះសម្មាសម្ពុទ្ធអង្គនេះ គេក៏មានចិត្តមួយហួងហែងព្រះពុទ្ធោវាទរបស់ព្រះអង្គយ៉ាងក្រៃលែង, គ្រប់រូបប្រាថ្នាឲ្យព្រះពុទ្ធ

សាសនាមានអាយុវែងហួស៥.០០០ ព្រះវស្សា ហើយសូមឲ្យមានវឌ្ឍន៍យ៉ាងប្រសើរ, មានការលូតលាស់ដុះដាលយ៉ាងពិសេស ៗ គេយល់ថា បើព្រះពុទ្ធសាសនាមានជីវិតលើស ៥.០០០ ព្រះវស្សា គេនឹងបានអាស្រ័យជាយាននាំទៅរកកន្លែងបរិសុទ្ធស្អាត ក្នុងកាលដែលគេអន្ទោកអន្ទោល ទៅក្នុងភពធំភពតូចនៃសង្សារវដ្តនេះ ៗ



ក្បួនហែរកំពុងប្រជុំលើថ្នល់ខាងជើងដើមពោធិព្រឹក្ស ដើម្បីហែរប្រទក្សិណព្រះស្តូបនឹងពោធិព្រឹក្ស ។

ក្នុងវារៈដែលជិតគ្រប់ ២.៥០០ ព្រះវស្សា ប្រជាជនខ្មែរទូទៅមានសេចក្តីរីករាយរកអ្វីប្រៀបគ្មាន, គេញាប់ញ័រក្នុងដួងចិត្ត ដែលគេបានឆ្លងផុតឧបសគ្គនានាហើយបានរស់រានមានជីវិត ទាន់ឃើញព្រះពុទ្ធសាសនាក្នុងរយៈនេះ បើគេពោលតាមពុទ្ធទំនាយថាមិនងាយនរណាអាចបានជួបប្រទះដូចគេណាស់ ៗ គ្រប់រូប កាលដែលឆ្លងផុតគ្រោះថ្នាក់ផ្សេងៗ គេតាំងចិត្តមុតមាំជាបំផុត ថានឹងធ្វើបុណ្យឆ្លងជោគជ័យនៃជីវិត នឹងជោគជ័យនៃព្រះពុទ្ធសាសនាដែលបានកន្លងមកដរាបដល់គ្រប់២.៥០០ ឆ្នាំ ហើយពុំមានឧបសគ្គណាអាចធ្វើឲ្យព្រះពុទ្ធសាសនាវិនាសទៅឡើយ ៗ

ជាជោគល្អណាស់; នៅពេលថ្មីៗនេះអាស្រ័យដោយការយកព្រះទ័យទុកដាក់នៃ

សម្ដេចព្រះឧបយុវរាជ ជាបិតាឯករាជ្យជាតិ, ហើយជាអគ្គពុទ្ធសាសនូបត្ថម្ភ ពិធីដែលប្រកបនឹងសម្ពោធខួបព្រះពុទ្ធសាសនាគំរប់ ២.៥០០ ព្រះវស្សា ក៏បានកើតឡើងសមតាមមនោសញ្ចេតនានៃប្រជាពលរដ្ឋខ្មែរទាំងស្រុង ដោយសម្ដេចព្រះឧបយុវរាជ ទ្រង់មានព្រះរាជបំណងឲ្យរដ្ឋាភិបាលជួយឧបត្ថម្ភផង ។ គេចាំបានថា សម្ដេចទ្រង់ចាត់ឲ្យសហជីវិន ទ្រិញ-ព៉ាញ រដ្ឋលេខាធិការនៅក្រសួងធម្មការនិងឃោសនាការ ព្រាងធ្វើគ្រោងការដើម្បីញ៉ាំងពិធីខួបព្រះពុទ្ធសាសនានៅពេលឆ្នាំក្រោយនេះ ឲ្យបានរុងរឿងជាពិសេស ។

សូមជម្រាបថាសហជីវិន ទ្រិញ-ព៉ាញ កាលទទួលព្រះបញ្ជា ក៏បានតាំងគ្រោងការនិងតាំងគណកម្មាធិការសំរាប់ចាត់ពិធីបុណ្យទៅដោយសេចក្ដីខ្នះខ្នែងយ៉ាងពេញទី ។ សហជីវិនបានចាត់តម្រូវវរជនជាគណកម្មាធិការគួរឲ្យសង្ឃឹមបានថា នឹងមានសម្ភាពយ៉ាងប្រពៃ ។

គួរឲ្យកត់សំគាល់បានថា សម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយកមហានិកាយ និងព្រះសុធម្មាធិបតីសង្ឃនាយកស្ដីទីគណធម្មយុត្តិ ដែលមានព្រះធម្មត្រៃលោកាចារ្យ ថិតសិលោ កេត-គោ ជាតំណាង ហើយទាំងពីរព្រះអង្គជាអនុប្រធានកិត្តិយសក្នុងគណកម្មាធិការនោះ មុខជាអាចញ៉ាំងសមាជិកទាំងអស់ឲ្យចាត់ការទៅបានផល ជាទីពេញចិត្តនៃប្រជាជនដោយពិត ។ គេមានសង្ឃឹមយ៉ាងច្បាស់លាស់ថា ពិធីបុណ្យនេះប្រហែលនឹងកើតជាពិធីឧឡារិក ហើយពុំបាច់ទំពឹងលើថវិកាជាតិផង ដោយហេតុថាបុណ្យនេះ របស់ប្រជាពលរដ្ឋខ្មែរទាំងអស់គ្នា ហើយជាពិធីបុណ្យមួយដ៏ត្រកាលដែលពុំអាចមាននរណាបានធ្វើសូម្បីតែម្ដងក្នុងជីវិតរៀងខ្លួន ។

សូមបញ្ជាក់ថាចាប់តាំងពីថ្ងៃ១កើតដល់ថ្ងៃ ១៥ កើតខែវិសាខក្នុង ព. ស. ២.៥០០ ត្រូវនឹងថ្ងៃទី ១៣ ឧសភា ១៩៥៧ នោះ នៅប្រាសាទអង្គរវត្តដែលជាអច្ឆរិយវត្ថុទី ៧ នៃសាកលលោក, នឹងពេញពោរទៅដោយភ្ញៀវពីគ្រប់ទិសានុទិសដែលមកមើលបុណ្យឆ្លងព្រះពុទ្ធសាសនា ហើយដែលនៅពេលនោះប្រាសាទអង្គរនឹងមានទេសភាពមួយគួរឲ្យទស្សនាពុំដែលជាយកអ្វីទៅប្រៀបធៀបបានទេ ។ ជាបន្ទាប់មកទៀត នៅព្រះរាជធានីភ្នំពេញក៏នឹងផ្លាស់ទេសភាពដែរ ដោយហេតុនឹងមានពិធីសម្ពោធឆ្លងព្រះចេតិយបញ្ចុះព្រះបរមសារីរិកធាតុ ដែលតាំងនៅមុខស្ថានីយ៍រថភ្លើងចំនួន ៣ថ្ងៃ បញ្ចូលទៅក្នុងពិធីបុណ្យឆ្លង ២.៥០០ ព្រះវស្សានៃព្រះពុទ្ធសាសនានោះផង ។

សេចក្ដីពិត, បុណ្យឆ្លងព្រះពុទ្ធសាសនា គំរប់ ២.៥០០ ព្រះវស្សានេះគឺមានតែមួយដង ហើយអ្នកដែលរស់នៅទាន់ ២.៥០០ ព្រះវស្សាដែលមិនងាយនោះ, គឺមានពេលមួយដងហើយដែលធំបំផុត ដើម្បីគោរពចំពោះព្រះពុទ្ធសាសនា ។

×

(នៅមានត)

× ×

## ស្ថានការណ៍នៅសហភាពភូមា (ត)

នៅទីផ្សារផ្សារគ្រប់កន្លែង មានទីក្រុងរង្គូនជាដើមគេតែងឃើញតែងជួបប្រទះប្រជាជនភូមារៀបចំតាក់តែងទំនិញលក់ដូរ ។ ប្រជាជនបរទេស ដែលជ្រៀតជ្រែកចូលទៅនៅអាស្រ័យប្រកបអាជីវភាពក្នុងប្រទេសនោះ ទោះយ៉ាងប្រជាជនជាតិឥណ្ឌាក្ដី ចិនក្ដីក៏មានដែរ តែថាប្រជាជនទាំងអស់នោះ ពុំអាចវាតមុខវាតអំណាចស្កាត់ដំណើរបណ្ដាមុខរបរគ្រប់យ៉ាងមានពាណិជ្ជកម្មជាដើមរបស់ប្រជាជនសញ្ជាតិភូមាបានឡើយ ព្រោះថានៅប្រទេសភូមា ប្រជាជនជាម្ចាស់ប្រទេសទាំងតូច-ធំ ទាំងមន្ត្រីទាំងរាស្ត្រ ដើរមុខប្រជាជនបរទេសដែល

ចូលទៅសំណាក់អាស្រ័យ ប្រកបអាជីវកម្មជាដរាប, តួយ៉ាងដូចជាប្រជាជនចិននៅប្រទេសខ្មែរយើង ជាតិចិនធ្វើការរកស៊ីប្រកបមុខរបរគ្រប់យ៉ាងរត់មុខប្រជាជនជាតិខ្មែរជាដរាប គឺប្រជាជនខ្មែរដែលជាម្ចាស់របស់ប្រទេស ដើរក្រោយជាអាចិន្ត្រៃយ៍ ទាំងសម្ដែងអាកប្បកិរិយា ក្រទីក្រទាក្រអឺតក្រទមចំពោះប្រជាជនខ្មែរជាម្ចាស់ប្រទេស ហាក់ដូចជាកម្មករ (ជើងឈ្នួលទៀតផង, ទាំងមិនសូវទទួលប្រតិបត្តិអនុវត្តទៅតាមច្បាប់សម្រាប់ប្រទេសឡើយ ព្រោះនៅគ្រប់តម្បន់ផ្សារផ្សារតូចធំ ក្នុងឃុំភូមិស្រុកខេត្តនៃប្រទេសខ្មែរទាំងមូល គេតែងជួបប្រទះតែសញ្ជាតិចិនជាមមាញឹក, ឯប្រជាជនជាតិខ្មែរងើបមុខពុំទាន់រួចនៅឡើយ ។

១ ទៀតប្រជាជនភូមាភាគច្រើន ពេញចិត្តរកស៊ីធ្វើជំនួញតួយ៉ាងខាងមុខរថយន្ត គេនាំគ្នាបង្កើតសមាគមច្រើនយ៉ាងណាស់ក្នុងសមាគមនីមួយ ៗ មានសមាជិកយ៉ាងតិច ៥០០ រូបឬ ១០០០ រូបបណ្ដាសមាជិកទាំងនោះ ត្រូវចូលហ៊ុនប្រាក់កាសគ្នាខ្លះ ១០០ រូពី, ២០០ រូពី, ១០០០ រូពីក៏មាន ។ល។ ហើយទិញរថយន្តសម្រាប់ដឹកទំនិញ, សម្រាប់រថឈ្នួល, តាមខេត្ត ស្រុក ក្រុង ឃុំ ភូមិ មានសញ្ញាផ្សេងៗគ្នា រថយន្តខ្លះជាក់សញ្ញាជារូបដំរីស-ក្រហម,-សេះសរ-ក្រហម, នាគសរ-ក្រហម, រូបទន្សាយ, រូបប្រកង់ជាដើម ស្ទើរតែប្រជាជនសញ្ជាតិភូមាទាំងអស់ ។ បណ្ដាសមាគមនីមួយៗ មានគណៈកម្មការច្រើនរូប ពួកខ្លះនៅធ្វើការប្រចាំកន្លែងសមាគម, ខ្លះទៅត្រៀមចាំពិនិត្យផែកនេះសុំប្រាក់ពីអ្នកជួលជិះ (អ្នកដំណើរ) ។ មុខជំនួញគ្រប់យ៉ាងដែលជាផលិតផលនៅក្នុងប្រទេសគេនោះ ស្ថិតនៅលើកណ្ដាប់ដៃនៃសមាគមជាតិគេទាំងអស់ ។ ឯសញ្ជាតិជនដទៃ មិនអាចដេញដើង ឬជ្រៀតជ្រែកមុខមាត់បានឡើយ ។ ចុះហេតុ

ដូចបានជាសមាគមគេ មានជំហររឹងប៉ឹងម៉្លេះ ? កាលបើគេបង្កើតឡើងបានហើយ មិនអាចរលំរលាយទៅវិញតើដោយហេតុអ្វី ? ។ ឆ្លើយថាបានជាដូច្នោះ មកពីសមាជិកដែលចូលហ៊ុនគ្នាធ្វើការ យកចិត្តទុកដាក់ក្នុងកិច្ចការ សន្តានចិត្តត្រង់មិនបំបាត់គាង ឬស៊ីឡបរវាងគ្នា ទោះបីសមាជិកទាំងនោះមានសមត្ថភាពខ្ពស់ទាបជាងគ្នាយ៉ាងណាក៏ដោយ ។ តាមការណ៍ពិតឲ្យឈ្មោះថាប្រជាជនជាតិគេ គឺគេរាប់អានគ្នាណាស់មិនសូវមាក់ងាយគ្នា មិនបៀតបៀនគ្នាទេ ទាំងចេះរក្សាចិត្តថ្លើមគ្នាទៅវិញទៅមកផង ។ ទោះបីមានការថ្នាំងថ្នាក់ ដោយរបស់គ្អីនមួយៗក្តី គេប្រើអាការអត់ធ្មត់ ការអត់សង្កត់ដោយច្រើន មិនបណ្តោយឲ្យរបស់គេនោះៗរីកធំទៅជាដុំកំភួនឡើយ ។

៤– អំពីគ្រឿងប្រដាប់ប្រើប្រាស ៖ ប្រជាជនភូមាប្រកាន់ខ្ជាប់នូវទំនៀមទម្លាប់ជាតិបូរាណ ចំពោះវត្ថុប្រើប្រាសគ្រប់យ៉ាង ដូចជាសំលៀកបំពាក់សម្រាប់បុរស ឬសំលៀកបំពាក់សម្រាប់ស្ត្រី ទោះបីក្មេង-ចាស់កម្លោះក្រមុំក៏ដោយក៏ដូចគ្នាទាំងអស់ គឺសំលៀកបំពាក់សម្រាប់បុរសទោះបីអ្នកនោះ មានភ្នាក់ងារជារាជការក្តី ជាបណ្តារាស្ត្រក្តី ត្រូវប្រើតែបែបមួយខុសគ្នាពណ៌ទឹងវត្ថុដែលថ្លៃថោកជាងគ្នាប៉ុណ្ណោះ មិនប្រើសំពត់ពណ៌ទៅជាដាច់ខាត ។ ចំណែកខាងបុរសពាក់អាវបំពង់កខុប ស្លៀកសារុង ពាក់កន្ទបដែលត្បាញដោយគ្រៀសឬស្សី ពាសដោយក្រណាត់សំពត់ពណ៌ផ្សេងៗ មានពណ៌លឿង-ក្រហមទឹងពណ៌ផ្កាឈូក ពណ៌ផ្កាត្រកៀតជាដើមប៉ុណ្ណោះ ទោះបីនៅក្នុងប្រទេសរបស់ខ្លួនក្តី ធ្វើដំណើរទៅកាន់នានាប្រទេសក្តីក៏ប្រើទៅតាមធម្មតា ។ ឯកន្ទបនោះមានបន្ទាន់ក្រណាត់បន្តិចសំយុងចុះទៅខាងស្តាំហាក់ដូចជាត្រចៀក (របៀបនេះមិនដឹងជាមានសញ្ញាដូចម្តេចពុំបានដឹងដោយជាក់ច្បាស់) ។

ចំណែកស្រីឯទៀតសោត ក៏ប្រើសំលៀកបំពាក់តែបែបមួយដែរ គឺពាក់អាវពណ៌ផ្សេងៗ មានសាច់ស្ដើងដៃវែងមានទ្រនាប់ (អៀម) ខាងក្នុងជាដរាប ។ ឯសំពត់ទៀតសោតគេនិយមប្រើសំពត់សំឡូយ ពណ៌ផ្សេងៗ ជាសំពត់ក្បាញលាយបម្រុះក៏មាន ក្បាញលាតប្រដាប់ដោយពុម្ពផ្កាក៏មាន ។ ឯការស្លៀកសំពត់ទៀតសោត ច្រើនប្រើសំពត់ ២ ជាន់សំពត់ជាន់ទី ១ មានសាច់ក្រាស, សំពត់ជាន់ទី ២ មានសាច់ស្ដើង ។

ម្យ៉ាងទៀត ប្រជាជនទាំងអស់ និយមប្រើយាមក្បាញអាយដែលប្រជាជនជាតិគេធ្វើនៅប្រទេសភូមា ទោះបីបុរសក្ដីស្ត្រីក្ដីកម្លោះ ក្រមុំ-ក្មេងចាស់ក្ដី ក៏និយមប្រើតែបែបមួយ សម្រាប់ដាក់ប្រដាប់ប្រដាធ្វើដំណើរតាមផ្លូវ, ដ៏ហោចទៅសូម្បីពួកនិស្សិតសាលាទោះបីថ្នាក់ណាក៏ដោយ អនុលោមប្រើតែបែបមួយ ដូចជាប្រជាជនប្រទេសខ្លះៗ ដែលនិយមប្រើហិបស្បែកឬកាតាបដែលមានធុនផ្សេងៗដែរ ។ ប្រជាជនទាំងអស់មិននិយមប្រើកាតាបជាដាច់ខាត ព្រោះគេយល់ឃើញថាកាតាបជារបស់បរទេស និងជាវត្ថុមានតម្លៃច្រើនផង, ដោយយល់ថាវត្ថុទាំងអស់នោះ ពុំទាន់កើតមានក្នុងប្រទេសគេផង, ។ ឯសំលៀកបំពាក់ទៀតសោតទោះបីពួកជាងអ្នកកាត់ដេរបេះក្រៃឡែឲ្យមានបែបផែន ឲ្យមានស៊ីវិល្បទៅតាមកាលទេសៈសម័យលោកនិយមយ៉ាងណាក៏ដោយ ក៏ប្រជាជនទាំងនោះមិននិយមប្រើទាំងមួកទៀតក៏ដូចគ្នា ស្រេចហើយនូវសារុងអាវកុឌប និងកន្ទបមួយប៉ុណ្ណោះ ។

៦– គ្រឿងស្អិតស្អាងគ្រាងកាយ៖ នៅសហភាពភូមាប្រជាជនភាគច្រើនណាស់ដែលមិននិយមប្រើម្សៅ 'ទឹកអប់, ក្រែម' ថ្នាំលាបលនក្រចក, ទោះបីវត្ថុទាំងនោះមានម៉ាក . ធុនយ៉ាងណាក៏ដោយចុះ ក៏គេមិននិយមប្រើ ។ (នៅមានត)



ពុទ្ធទស្សនៈ(គ)

ន័យនេះបើគិតពិចារណាឲ្យច្បាស់លាស់ទៅថា: ទេវតាមិនមែនឲ្យយើងសម្លាប់សត្វយកទៅបូជាជូនខ្លួនទេ ៗ ចំណែកការបរិភោគសាច់សត្វ ក៏ជាធម្មតារបស់មនុស្សដែលព្រះអង្គទ្រង់ជ្រាបថា: លំបាកលើកលែងបានណាស់ ទើបទ្រង់បញ្ញត្តថា: មិនមែនឲ្យសម្លាប់ដោយដៃខ្លួនឯងប៉ុណ្ណោះ មិនមែនទ្រង់ហាមថា: មិនឲ្យបរិភោគសាច់សត្វនោះទេ ៗ

ការផ្សេងបាកគ្រប់ឋាន: ដូចជាអ្នកទទួលរបស់បញ្ញើ ឬអ្នករក្សាទ្រព្យសម្បត្តិរបស់

បុគ្គលដទៃ ហើយយកទ្រព្យនោះទៅចាយវាយប្រើប្រាស់ខ្លួនឯង; ការធ្វើប្រាក់នឹងធនបត្រប្លមឬធ្វើត្រាដាសចាយបន្លំ, ការល្បួងលួងលោមឲ្យគេចូលទុនធ្វើការជំនួញ, ហើយយកប្រាក់នោះទៅចាយវាយជាប្រយោជន៍របស់ខ្លួន ចាត់ថាជា អទិន្នាទាន ។

បំណែកការប្រព្រឹត្តខុសក្នុងកាមនោះ មិនមែនសំដៅចំពោះតែការធ្វើអាក្រក់នឹងប្ដីប្រពន្ធអ្នកដទៃនោះទេ ការលបលួចធ្វើអាក្រក់នឹងបុរសស្ត្រីដែលមាតាបិតា ឬអ្នកគ្រប់គ្រងនៅមិនទាន់បានអនុញ្ញាត ក៏ឈ្មោះថាប្រព្រឹត្តក្នុងកាមដូចគ្នា ។

៥– សម្មាអាជីវៈ ប្រែថា: ចិញ្ចឹមជីវិតត្រូវ បានដល់ការចិញ្ចឹមជីវិតត្រូវក្នុងផ្លូវសុចរិតនឹងត្រូវតាមទំនៀម ។ ការលក់ដូរស្រា ថ្នាំស្រវឹង ការតាំងរោងបនស្រីពេស្យា ការសម្លាប់សត្វលក់ជាកក្កុហា សូម្បីមិនខុសច្បាប់ផែនដីពិត , តែច្បាប់សាសនាចាត់ថាជាមិច្ឆាជីវៈទាំងអស់ ។

ឯការលក់មនុស្សនឹងការតាំងបនឲ្យមនុស្សលេងល្បែងភ្នាល់ ។ល។ ជាផ្លូវខុះទាំងក្នុងព្រះពុទ្ធសាសនា ទាំងក្នុងច្បាប់អាណាចក្រ ។

៦– សម្មាវាយាមៈ ព្យាយាមត្រូវ ; បានដល់ការព្យាយាមក្នុងផ្លូវញ៉ាំងកុសលធម៌ឲ្យកើតឡើងឲ្យចំរើនឡើង នឹងការញ៉ាំងបាបធម៌មិនឲ្យកើតឡើងគឺថាឲ្យសាបសូន្យទៅ ។ ក្នុងសន្ដានចិត្តយើងគ្រប់គ្នា រមែងមានទាំងកុសលធម៌ទាំងបាបធម៌តិចខ្លះច្រើនខ្លះ, ជានាទីរបស់យើងគ្រប់គ្នាដែលព្យាយាមប្រកាន់មាំក្នុងកុសល ដែលយើងមានហើយឲ្យតាំងនៅឋិតថេរ ឬឲ្យចំរើនឡើង ហើយគួរកាត់បង់នូវបាបធម៌ឲ្យអស់ទៅជាលំដាប់ កុំបង្ក— បង្កើតបាបធម៌ឲ្យកើតឡើង ។

៧- សម្មាសតិ សេចក្ដីរលឹកត្រូវ បានដល់ការរលឹកធ្វើឲ្យស្ងប់រាគៈ, ទោសៈ,

មោហៈ, នឹងការរលឹកមិនធ្វើឲ្យកើត រាគៈ ទោសៈ មោហៈ ។ រាគៈនោះយ៉ាងគ្រោតគ្រាតបំផុត គឺកាមរាគៈ បានដល់សេចក្ដីប្រាថ្នាដោយអំណាចនៃកិលេសកាម; មានរាគៈដែលល្អិតទៅទៀត២យ៉ាង ក៏ចាត់ថាជារបស់មិនល្អដូចគ្នា គឺរូបរាគៈ បានដល់សេចក្ដីជាប់ចិត្តនៅក្នុងរូបធម៌ ដូចជាជាប់ក្នុងបុគ្គលរូបខ្លះឬក្នុងកស្ដុការណាមួយ; ម្យ៉ាងទៀតហៅថា អរូបរាគៈ បានដល់ការជាប់ចិត្តក្នុងអរូបធម៌ដូចជាពេញចិត្តក្នុងសុខវេទនាជាដើម ។

ទោសៈ ច្រើនតែប្រែដោយខ្លីថា "ក្រោធ" តែបើតាមពិតក្រោធជាចំណែកមួយនៃទោសៈប៉ុណ្ណោះ សេចក្ដីគិតប្រទូស្តរ៉ាយគ្រប់ស្ថាន ដូចជា ឥច្ឆា, ព្យាបាទ អាឃាត ទាំងនេះសង្គ្រោះចូលក្នុងទោសៈទាំងអស់ ។

មោហៈ បានដល់សេចក្ដីវង្វេង ដូចជាមនុស្សដែលវង្វេងងងឹតងងុលមិនដឹងដល់កាលជាដើម ។

៨. សម្មាសមាធិ តាំងចិត្តត្រូវបានដល់ការការនាសង្កត់ចិត្តឲ្យចុះស៊ប់ក្នុងផ្លូវប្រាថ្នាគិតក្នុងផ្លូវបំណានល្អដល់បុគ្គលដទៃ នឹងក្នុងផ្លូវធ្វើឲ្យសាបសូន្យសេចក្ដីវង្វេង, ធ្វើចិត្តឲ្យនឹងតែម្យ៉ាង តែនៅមិនទាន់ចុះស៊ប់ដោយពិត១ ហៅថាឧបចារសមាធិ" គឺសមាធិគ្រាន់តែជាគណៈ១; កាលណាធ្វើចិត្តឲ្យនឹងស្ងប់ស្ងាត់បានហើយ ទើបឈ្មោះថា អប្បនាសមាធិ គឺសមាធិដ៏ល្អិតសុខុម ។

អរិយសច្ច៤ប្រការនេះឯង ជាធម៌ដែលព្រះពុទ្ធជាម្ចាស់របស់យើងបានត្រាស់ដឹងឈ្មោះថា ព្រះអង្គបានចាក់ធ្លុះអនុត្តរសម្មាសម្ពោធិញ្ញាណ គឺបញ្ញាត្រឡេតមើលឃើញសេចក្ដីពិតយ៉ាងសំខាន់៤ប្រការ រកបុគ្គលដទៃប្រៀបមិនបាន ជាធម៌ដែលមិនមាន

បុគ្គលណាមួយ បានឃើញមុនព្រះអង្គឡើយ ។

១ ដែលយើងទាំងឡាយគួរដឹងនូវព្រះគុណរបស់ព្រះពុទ្ធជាម្ចាស់ដ៏ខ្ពង់ខ្ពស់នោះគឺ ព្រះអង្គបានត្រាស់ដឹងធម៌ដ៏វិសេសហើយ ព្រះអង្គមិនមែនលាក់លៀមទុកសម្រាប់ចំពោះតែព្រះអង្គឯងប៉ុណ្ណោះទេ, ដោយអំណាចព្រះមហាករុណាដ៏ធំទូលាយប្រៀបដូចទន្លេសមុទ្រដ៏ធំ ដែលគេរកកោះត្រើយច្រាំងគ្មានដូច្នោះ ។ ព្រះអង្គទ្រង់បានប្រកាសប្រៀនប្រដៅប្រាប់ពន្យល់ធម៌វិសេសនោះដល់វេនេយ្យនិករដោយមិនរើសមុខ ដូចជាប្រទានសម្បត្តិដ៏ប្រសើរបំផុតជាងភោគសម្បត្តិទាំងពួងទុកឲ្យឋិតនៅក្នុងលោក ជាគ្រឿងឃុំគ្រងលោក នឹងប្រលោមចិត្តមនុស្សនិករគ្រប់ប្រភេទជាសាធារណៈប្រយោជន៍ រកប្រយោជន៍ដទៃប្រៀបគ្មាន ។

បំណែកយើងគ្រប់គ្នា ដែលជាអ្នកប្រកាន់ខ្លួនថាជាពុទ្ធសាសនិក គួរជាអ្នកប្រកបដោយកតញ្ញូកតវេទី កាលបើដឹងថា: ព្រះពុទ្ធអង្គទ្រង់មានឧបការគុណដល់យើងគ្រប់គ្នាហើយ គួរតាំងចិត្តតបស្នងសងព្រះគុណ ដោយតាំងចិត្តប្រព្រឹត្តតាមព្រះបរមពុទ្ធោវាទ ដោយពេញសតិបញ្ញានឹងសេចក្តីអង់អាច ។ (នៅមានត)

## សេចក្តីរាយការណ៍អំពីការប្រជុំនៃគណៈកម្មាធិការ ទីប្រឹក្សាពុទ្ធគយា ថ្ងៃទី ១៩ មីនា ១៩៥៦ (ត)

លើកទី ៤ កាលពីថ្ងៃទី ១៩-៦-៥៥, លើកទី ៥ កាលពីថ្ងៃទី ៩ ធ្នូ ៥៥ និងពេលនេះជាលើកទី ៦ ។

ដោយគណៈកម្មាធិការយល់ថា មិនអាចនឹងចាត់ចែងរៀបចំទីស្ថានពុទ្ធគយាតែ

ម្នាក់ឯងបាន ទើបកាលពី គ.ស. ១៩៥៤ រដ្ឋាភិបាលពិហារបានផ្ដើមចាត់ចែងជាវយកទីដីទុកសម្រាប់បូជនីយស្ថានមានទំហំច្រើនជាង ៤៤ ហិកតារគឺ៖

ក– ទីដីទំនេគ្មានផ្ទះសំបែងដែលជាលានព្រះមហាចេតិយ ទាំងទីដីដែលមានផ្ទះគ្រឹះស្ថានមិនជាទីគួរទស្សនា ហើយត្រូវជួសជុលឡើងវិញ ;

ខ– ផ្ដល់ទីកន្លែងឲ្យប្រជាជនដែលត្រូវឲ្យរើថយចេញពីកន្លែងដើម;

គ– សាងសង់ផ្ទះសំណាក់ថ្មី ៗ ល ៗ

ឃ– ធ្វើកិច្ចសន្យាជួលដីដ៏សមគួរឲ្យរដ្ឋាភិបាលបរទេស ។ ទីដីដ៏ធំទូលាយដែលបានមកនេះ មានតម្លៃប្រមាណ ២០០.០០០ រូបិយ ។ រដ្ឋាភិបាលមានអំណាចត្រួតត្រាលើទីកន្លែងវត្តខាងនៃពុទ្ធស្ថានទាំងអស់ ។

ក្នុងខែមេសា ១៩៥៥ រដ្ឋាភិបាលបានតម្រូវឲ្យគណកម្មាធិការចាត់ការរៀបចំធ្វើពិធីបុណ្យពុទ្ធជយន្តិ (ពិសាខបូជា) សម្រាប់ គ.ស. ១៩៥៦ ។ គណៈកម្មាធិការនេះបានទៅនិត្យដល់ទីកន្លែងជាពុទ្ធគយា, រាជគ្រិះនិងលន្ទាខែទសភា ១៩៥៥ ។ ការជួសជុលតុបតែងទីព្រះមហាចេតិយពុទ្ធគយាអស់តម្លៃមិនតិចជាង ៤០០.០០០ រូបិយ គឺការបំណាយគ្រាដំបូងអស់ចំនួន ១០០,០០០ រូបិយ និងគ្រាខាងក្រោយមកអស់ ៣០០.០០០ រូបិយ ។ មានកិច្ចការចាំបាច់ដទៃទៀតដែលត្រូវធ្វើនៅទីពុទ្ធគយា និងទីកន្លែងខាងដែលនឹងអស់តម្លៃប្រហែល ៨០០.០០០ រូបិយ ។ មានគណៈកម្មាធិការអ្នកជំនាញការមួយទៀតប្រកបដោយសមាជិកខ្លះនៃគណៈកម្មាធិការ ព្រះមហាចេតិយពុទ្ធគយា និងអ្នកជំនាញការខាងបច្ចេកទេសជាសមាជិក បានត្រូវតែងតាំងឡើងដើម្បីជាជំនួយដល់គណៈកម្មាធិការ

ព្រះមហាចេតិយ ។ តាមសេចក្តីស្នើសុំ នៃគណៈកម្មាធិការទាំងពីរនេះ រដ្ឋាភិបាលនៃប្រទេសឥណ្ឌា បានសម្រេចឲ្យខ្ចីប្រាក់ចំនួន ៣០០.០០០ រូបិយ ;

ចំណែកខាងរដ្ឋាភិបាលពិហារចំនួន ១០០.០០០ រូបិយ សម្រាប់បដិសង្ខរណ៍កិច្ចនៃព្រះមហាចេតិយនឹងទីជុំវិញ ។ គណកម្មាធិការទាំងនេះបានរៀបចំទីស្ថានពុទ្ធគយានឹងទីជិតតំបន់គយា ( ក្រៅពីពុទ្ធគយា ) ។

តាមគ្រោងការដែលត្រូវចាត់ចែងទីកន្លែងទាំងនេះត្រូវមានការចំណាយដូចនិវេទនៈតទៅនេះ ៖

និវេទនៈ « ក » ចំពោះព្រះមហាចេតិយពុទ្ធគយារួមតម្លៃទាំងអស់ ៤០០.០០០ រូបិយ ។

និវេទនៈ « ខ » ចំពោះកិច្ចការរៀបចំដទៃៗក្នុងទីពុទ្ធគយា រួមតម្លៃទាំងអស់ ១.៦៧៦.០០០ រូបិយ ។

និវេទនៈ « គ » ចំពោះកិច្ចការដទៃទៀតក្នុងតំបន់គយា រួមតម្លៃទាំងអស់ ៤៩៩.៨០០ រូបិយ ។

គណៈកម្មាធិការមិនអាចនឹងរៀបរាប់អំពីកិច្ចការទាំងនេះដោយសព្វគ្រប់បានព្រោះនៅកំពុងធ្វើ ប៉ុន្តែសង្ឃឹមថានឹងបានហើយស្រេចសព្វគ្រប់ទាំងអស់នៅចុងខែឧសភាមុខនេះ ។ ប្រសិនបើពុំបានជំនួយអំពីរដ្ឋាភិបាលឥណ្ឌា នឹងរដ្ឋាភិបាលនៃរដ្ឋពិហារទាំងខាងហិរញ្ញវត្ថុទាំងបច្ចេកទេសកិច្ចការទាំងនេះក៏ពុំមានរូបរាងប្រាកដឡើយដោយពិត ។ ឯការរៀបចំសម្រាប់ផ្តល់សេចក្តីសុខស្រួលបូជនិយេសកដែល នឹងមកកាន់ពុទ្ធស្ថានពុទ្ធគយាក្នុងឆ្នាំនេះ ក៏មុខជានឹងបានសម្រេចក្នុងរវាងឆាប់ៗនេះដែរ ។ល។

បន្ទាប់ពីសេចក្ដីរាយការណ៍នេះ លោកអនុប្រធានាធិបតីនៃប្រទេសឥណ្ឌៀ បានថ្លែងសេចក្ដីចំពោះគណៈកម្មាធិការ ។

នៅខាងដើមលោកបណ្ឌិតរាធាគ្រិស្ណាន បានបញ្ជាក់ពីការប្រជុំនេះដែលជាការរួបរួមនៃអ្នកកាន់សាសនាព្រះពុទ្ធនិងសាសនាហិណ្ឌូក្នុងទីជាមួយគ្នា ហើយបានលួងពន្យល់ពីពាក្យប្រៀនប្រដៅនៃសាសនាទាំងឡាយ ដែលសុទ្ធតែមានគោលបំណងដឹកនាំឲ្យមានការរួបរួមបែបនេះឯង ។ លោកពោលថាៈ ពុទ្ធគយាជាទីពិសិដ្ឋនៃគ្រប់សាសនាទាំងអស់ គប្បីជាទីប្រជុំប្រកបដោយមិត្តភាពបែបនេះជាដរាបរៀងទៅ ។ លោកពោលថាយើងទាំងអស់សព្វថ្ងៃរស់នៅក្នុងពិភពលោកប្រកបដោយអនិច្ចតាធម៌ ពេលនេះជាការគួរដល់ប្រជាជាតិទាំងអស់ដែលគប្បីក្រោកឡើង ហើយបែរមុខឆ្ពោះទៅរកសច្ចៈធម៌ ។ ពេលវេលាតែងធ្វើជាម្ចាស់នៃយើងរាល់គ្នា យើងត្រូវក្រោកឡើងឈប់នៅក្រោមអំណាចពេលវេលាតទៅទៀត គឺថាកុំឲ្យពេលវេលាកន្លងទៅទទេ ហើយត្រូវដើរតាមផ្លូវដែលគ្មានពេលវេលា, គ្មានលក្ខខណ្ឌ, ដែលមិនច្របូកច្របល់ ផ្លូវទៅកាន់ព្រះនិព្វានដែលជាស្ថានប្រកបដោយជ័យជំនះលើពេលវេលា ។ លោកបានថ្លែងបន្តទៅទៀតថា ទីស្ថានទាំងឡាយមានពុទ្ធគយាជាដើម មិនមែនបានទៅជាទីពិសិដ្ឋ ដោយសារអច្ឆរិយបុរសទាំងនោះឯង ។

លោកអនុប្រធានាធិបតីមានសង្ឃឹមថា អ្នកទាំងអស់គ្នានឹងអាចប្រតិបត្តិយ៉ាងម៉ត់ចត់តាមពាក្យប្រៀនប្រដៅរបស់ព្រះសម្ពុទ្ធបរមគ្រូ ប៉ុន្តែលោកបានរំលឹកថា យើងត្រូវសំអាតខ្លួនយើងឲ្យបានបរិសុទ្ធជាមុន ព្រោះពាក្យដែលគ្រាន់តែពោលថា ។

នៅមាន (ត)

## របនាវិលាសភិក្យភាសាអង់គ្លេស (ត)

### Common mistake (កំហុសស្រាលៗ)

1- Wrong use (ការប្រើខុស) of «both» in negative sentence (ក្នុងប្រយោគបដិសេធ) instead of (ជំនួសពាក្យ) «neither»

Don't say: BOTH of them did not go to school.

Say: NEITHER of them went to school.

(បណ្ដាអ្នកទាំងពីរ គ្មានអ្នកណាមួយទៅសាលារៀនសោះ)

But the word «both» must be used in Affirmative (ប្រយោគអត្ថពាក្យករណ៍)

Say: BOTH of them went to school.

(អ្នកទាំងពីរ បានទៅសាលារៀនហើយ)

2- Wrong use of word «also» or «too» in negative sentence instead of (ជំនួស) «either»

Don't say: John has not come ALSO (OR TOO)

Say: John has not come EITHER

(ចន ក៏មិនបានមកដែរ)

3- Wrong use of «and» in negative sentence instead of «OR»

Don't say: He did not speak loudly AND clearly.

Say: He did not speak loudly OR clearly.

(គាត់មិនបានពោលឲ្យខ្លាំងៗ ឬច្បាស់ៗ ឡើយ)

But we can regularly use «and» in Affirmative.

Say: He spoke loudly and clearly.

(គាត់និយាយឮៗ ហើយច្បាស់ៗផង)

4- វិធីប្រើពាក្យ «How do you do?» នឹង How are you?»; ពាក្យពីរប្រយោគនេះប្រើផ្សេងគ្នា; កាលបើគេសួរថា «How do you do?» មិនត្រូវឆ្លើយដោយពាក្យដទៃទេ, ត្រូវតបថា «How do you do?» ដដែល ។. ពាក្យ «How do you do?» នេះប្រៀបបាននឹងពាក្យខ្មែរថា "សួស្តី! ឬជំរាបសួរ!" កាលបើគេពោលថា "សួស្តី!" យើងក៏ត្រូវតបថា "សួស្តី!" ដូចគ្នាដែរ ។

តែបើគេសួរថា «How are you?», ត្រូវឆ្លើយតាមសភាពពិតរបស់ខ្លួនសុខ ឬទុក្ខ, ព្រោះពាក្យ «How are you?» ជាពាក្យសួរចង់ដឹងសុខទុក្ខ, ដូចពាក្យខ្មែរថា "លោកសុខសប្បាយទេឬ?" ។ បើយើងសុខសប្បាយ ត្រូវតបទៅវិញថា "O am quite welle. Thank you. And you?" គេច្រើនឆ្លើយ ហើយសួរបកទៅវិញដូច្នេះ ។ បើមិនសប្បាយ មានរោគយ៉ាងណាត្រូវតបយ៉ាងនោះ ។

Here ends the first lesson (ចប់សជ្ឈាយនៈទី ១ តែត្រឹមប៉ុណ្ណេះ ។

(មហាវីរៈបណ្ឌិតោ អាំ-សួន ហៅ ហម វិជ្ជាស្ថាននាលន្ទា ប្រទេសឥណ្ឌា)

# LESSON TWO

## I- To break down;

( to stop functioning; -said generally of motors and similarly mechanicall objects. )

1- Our car BROKE DOWN on the road, and we had to tow it to a garage.

NOTE= garage

2- The elevator (= lift) BROKE DOWN, and we had to Walk up to the tenth floor.

NOTE= ពាក្យ " elevator „

## II- To turn up;

( 1- to abandon; 2- to look for; 3- to discover; 4- to arrive.)

1- He made some effort to restore peace, but failing to do so, at length he TURNED IT UP. (នៅមានត)

# សជ្ឈាយនៈ ទី ២

មិនធ្វើការ ; មិនដើរ ; ខូច ;
ច្រើននិយាយចំពោះគ្រឿងយន្ត និងវត្ថុ
ដែលប្រៀបបានដោយគ្រឿងយន្ត ;

រថយន្តយើងខូចនៅកណ្ដាលផ្លូវ ហើយ
ត្រូវយើងអូសវាយកទៅឯយានដ្ឋាន
( កន្លែងជួសជុលកែរថយន្ត )

មានអត្ថន័យពីរយ៉ាង គឺកន្លែងចតរថ
យន្តឬរោងជួសជុល–កែរថយន្ត ។

ឧក្ខេបកយន្ត ( ជណ្ដើរទឹកក្រុត ) ខូច
ហើយ យើងត្រូវដើរឡើងទៅដល់ថ្នាក់
( ជាន់ ) ទី ១០ ។

ច្រើនប្រើដោយជនជាតិអាមេរិកាំង ;
អង់គ្លេសច្រើនប្រើពាក្យ " lift ,,, ប្រែ
ដូចគ្នា ។

១- លះបង់ ; ២- រកមើល ; ៣- ជួប
ប្រទះ ; ៤- ទៅដល់, មកដល់ ;

គាត់បានធ្វើនូវសេចក្ដីព្យាយាមខ្លះ
ដើម្បីកសាងសន្តិភាព, ប៉ុន្តែធ្វើពុំសម្រេច
ដូច្នោះ, នៅទីបំផុតគាត់លះបង់ព្យាយាម

# រឿងតុក្កតាធ្វើពីទធិជាតិ (ត)

ព្រះមហាក្សត្រមានព្រះបន្ទូលថា: «ស្វា, ឯងកុំខ្លាចអី! ។ យើងចាត់ឲ្យជីកអន្ទង់ក្រៅជុំវិញល្វែងដែលព្រះនាងនៅហើយ ព្រះនាងទុក្ខរ៉ីនអាចចៀសវាងនូវអន្តរាយគ្រោះថ្នាក់ផ្ទាន ។ នៅលើជញ្ជាំង, ពីលើអន្ទង់, យើងដាក់ទាហានឲ្យយាមល្បាតយប់ថ្ងៃហាមប្រាមកុំឲ្យព្រះរាជនីក្មេងចូលមកដល់ទីនេះ ។ យើងនឹងប្រគល់ឲ្យព្រះនាងទុក្ខរ៉ីននូវទាសីម្នាក់គេហើយថ្ងង់ផង ហើយស្វាតូចឆ្លាត ជាបុត្រចិញ្ចឹមព្រះរាជនីជាអ្នកមើលការថែទាំស្ត្រីទាំងពីររូប ។

ស្វាក៏ក្រាបបង្គំទូលព្រះមហាក្សត្រថា:

—« មហារាជ, បើដូចនេះទូលបង្គំសូមទ្រង់ព្រះរាជានុញ្ញាតទៅអញ្ជើញព្រះមាតាមកនៅទីនេះ » ។

ព្រះមហាក្សត្រទ្រង់មានព្រះរាជឱង្ការឲ្យហៅលោកនាយករដ្ឋមន្ត្រី ហើយទ្រង់ត្រាស់បង្គាប់ថា:

« លោកនាយក, ចាត់ចែងឲ្យគេរៀបចំព្រមទាំងតុបតែងឲ្យសមរម្យនូវល្វែងដែលគ្មានអ្នកណានៅក្នុងព្រះបរមរាជវាំង ។

លោកនាយកបានចាត់កម្មករជាមួយម៉ឺននាក់ឲ្យជួសជុលល្វែង ដែលទុកសម្រាប់ថ្វាយព្រះនាងទុក្ខរ៉ីនតែមួយថ្ងៃក៏ហើយស្រេច ។

ហើយព្រះនាងទុក្ខរ៉ីនទ្រង់ព្រះពស្ត្រសារីថ្មី, ដោះចោលនូវព្រះពស្ត្រកន្ទះចាស់, ទ្រង់ចាកចេញពីខ្ទមទ្រុឌទ្រោមតម្រង់ទៅកាន់ល្វែងមួយនៃព្រះបរមរាជវាំង ដែលព្រះនាងគង់នៅតាំងពីថ្ងៃនោះមក ។

x x x

ហើយម្តងនេះទៀត, ដូចជាអតីតកាល, ព្រះនាងទុក្ខរ៉ានីទ្រង់ផ្ទុំនៅលើព្រះខែនមាស ហើយទ្រង់សោយតែព្រះក្រយាតម្កល់នឹងសុវណ្ណភាជន៍ព្រះនាងទ្រង់អាចចែកទានទៅពួកអ្នកក្រីក្រលំបាក ហើយនឹងបូជានូវព្រះរាជទ្រព្យតាមព្រះទ័យទៅពួកអ្នកកំសត់ទុគ៌ត; នៅក្នុងព្រះបរមរាជវាំង គេច្រៀងសរសើរនូវភ័ពសំណាងនៃព្រះនាងទុក្ខរ៉ានី, ហើយក្នុងភូមិនីមួយ ៗ គេសំដែងអាកប្បកិរិយាគោរពចំពោះព្រះនាមរបស់នាង, ហើយនៅក្នុងព្រះរាជអាណាចក្រទាំងមូលគេចាត់ធ្វើពិធីបុណ្យជាទឡារឹក ដើម្បីព្រះកិត្តិយស ចំពោះព្រះនាង ។

X X X

## យាយអាប

តាំងពីព្រះនាងទុក្ខរ៉ានីទ្រង់វិលត្រឡប់មកកាន់ព្រះបរមរាជវាំងវិញ, ព្រះរាជនីក្មេងសុខរានីទ្រង់មានព្រះទ័យទោមនស្សជាខ្លាំងដូចជាភ្លើងឆេះរោលរាលពាសពេញព្រះអង្គ ។ មានមួយថ្ងៃ, ព្រះនាងទ្រង់ខ្ញាល់ពន់ពេកទ្រង់ចាត់ឲ្យហៅកល្យាណមិត្តនីរបស់ព្រះនាងគឺយាយអាបប្រញាប់ប្រញាល់មកជួបនឹងព្រះនាង ។

ព្រះរាជនីក្មេងទ្រង់មានបន្ទូលថា:

—“ ម្តេចទៅយាយឯងសុខសប្បាយជាទេឬ? ចូរយាយចិតជិតមក, យាយអញ្ជើញអង្គុយជិតខ្ញុំ...” ។

យាយអាបអង្គុយជិតព្រះរាជនីហើយទូលសួរព្រះនាងថា:

“ ព្រះនាង, ហេតុម្តេចក៏ទ្រង់ត្រាស់បង្គាប់ឲ្យហៅខ្ញុំម្ចាស់? ព្រះភ័ក្ត្រទ្រង់ទុក្ខព្រួយជាអនេក ខ្ញុំម្ចាស់បានឃើញទឹកព្រះនេត្របញ្ចេញពីព្រះចក្ខុនាង... ។ តើព្រះនាងទ្រ

មានការអ្វី ? » ។

ព្រះរាជនីទ្រង់មានបន្ទូលតបមកយាយអាបវិញថា:

« គ្មានអ្វីទេ, យាយ, កុំព្រះកិត្តិនាមនៃមេឃនឹងដី, គ្មានអ្វីទេ...មានតែទុក្ខពីន, ជាបច្ចាមិត្តនីរបស់ខ្ញុំវាវិលត្រឡប់មកកាន់ព្រះបរមរាជវាំងវិញហើយ ។ វាស្លៀកសំពត់សារីមាស, វាមកនៅកុងល្វែងម្ខាងនៃព្រះបរមរាជវាំង; វាត្រឡប់មកកាន់ឋានន្តរៈថ្មីជាព្រះស្នំឯកនៃព្រះមហាក្សត្រដូចដើមហើយ! ទុក្ខពីន, មេស្នំយាចកវាចង់សោយរាជ្យក្នុងព្រះបរមរាជវាំង, ហើយវាចង់ឲ្យខ្ញុំ, ព្រះរាជនីសុខ:, បាត់នាមបាត់ឈ្មោះពីទីនេះ!... ។

«ឱយាយជាទីស្រឡាញ់ខ្ញុំអើយ, កាលណាខ្ញុំគិតពីរឿងនេះ, ភ្លើងគឺទោសៈឆេះពេញពលសព្វសព៌ាង្គខ្ញុំ; កាលណាខ្ញុំពណ៌នាពីរឿងនោះ សេចក្តីសង្ស័យខ្ញុំក៏ផុតរលុតអស់; ខ្ញុំចង់ស្លាប់, ល្អជាជាង! ចូរយាយឲ្យឱសថពុលមកខ្ញុំ... ។ បច្ចាមិត្តនីរបស់ខ្ញុំដែលខ្ញុំស្អប់ខ្ពើមពន់ពេក, ទៅជាព្រះមហាក្សត្រទ្រង់សព្វព្រះរាជហឫទ័យស្រឡាញ់វា គោរពវា! ទេ, មិនសមទេ, ខ្ញុំមិនអាចទទួលនូវ...។

យាយអាបពោលថា:

—« គួរឲ្យខ្លាសណាស់ នាងមិត្តនីខ្ញុំ! មិនត្រូវបញ្ចេញព្រះវាចាបែបនេះពីបបូរមាត់ក្រហមឆ្អៅសោះ! មិនត្រូវគិតដូចនេះទេ! ម្តេចក៏នាងចង់លេបថ្នាំពុល? តែឥឡូវទុក្ខពីន ជាព្រះស្នំឯកព្រះមហាក្សត្រ, ស្អែកវាទៅជាស្នំយាចកជាគំរប់ពីរដងហើយ ។ តែនាងស្ថិតនៅជាដរាបព្រះរាជនីសុខ:(ស្លពីន) ។

# ជ័យប្រាជ្ញ (ត)

កុមារជ័យ ៖ ! ព្រះអង្គអើយ ! ទូលព្រះបង្គំមិនដឹងជាទៅទីពឹងអ្នកណាក្រៅពីព្រះអង្គទៀតទេ ការដែលទ្រង់បណ្ដេញទូលព្រះបង្គំយ៉ាងនេះ ទុកដូចជាទ្រង់បណ្ដាច់នូវខ្សែពិណយ៉ាងពីរោះរបស់ព្រះអង្គចោលចេញ ដោយទ្រង់យកអ្នកដេញជាប្រមាណ ។ នេះជាហេតុ១នាំឲ្យទូលព្រះបង្គំស្ដាយហើយស្ដាយទៀត មិនចេះអស់មិនចេះហើយ ។ សំឡេងពិណយ៉ាងពីរោះនោះមិនមែនមានប្រយោជន៍ដល់ពិណទេ គឺមានប្រយោជន៍ដល់ជាងអ្នកធ្វើពិណ ដល់ម្ចាស់ពិណ និងដល់អ្នកដេញពិណទេតើ គ្រាន់តែអ្នកដេញពិណនោះធ្វើមិនឲ្យពីរោះ ហេតុអ្វីក៏ទ្រង់បណ្ដាច់ខ្សែពិណចោល ។ ឯទូលព្រះបង្គំក្រោមល្អងធូលីព្រះបាទនេះទុកដូចជាពិណមួយរបស់ព្រះអង្គដែរ ។ សូមទ្រង់ព្រះមេត្តាប្រោសជួយទូលព្រះបង្គំផង ។ កុមារជ័យយំហើយក្រាបបង្គំទូលបណ្ដើរទាំងទឹកភ្នែកហូរហៀរសស្រាក់ ។

ព្រះមហាក្សត្រទ្រង់ទតឃើញកុមារជ័យមានសភាពដូច្នោះទ្រង់មានព្រះរាជហឫទ័យអាណិតកុមារជ័យពន់ពេក តែទ្រង់មានព្រះបន្ទូលមិនឲ្យដឹងព្រះទ័យថា នែ ! អាជ័យ ! អាឯងកុំមាត់ច្រើនពេក អប្បុកត្រចៀកអញណាស់ ត្រូវចេញពីវាំងអញឲ្យឆាប់ទៅ តែចំនៅតទៅទៀតអញនឹងយកទោសអាឯងឥឡូវ ៗ ចេញទៅ ៗ ៗ ៗ ៗ

X X X

កុមារជ័យក្រាបបង្គំព្រះមហាក្សត្រទាំងទឹកភ្នែក ហើយដើរសំដៅទៅមាត់ទ្វារឆ្ពោះទៅកាន់ផ្ទះរបស់ខ្លួន ។

ពួកសេវកាមាត្យទាំងឡាយដែលនៅខាងក្រៅព្រះបរមរាជវាំង លុះឃើញកុមារជ័យដើរចេញមក មានមុខក្រៀមក្រំដូច្នោះ ក៏ស្រដីទៅកាន់កុមារជ័យថា ម៉េចអាឯង !

ជឿអញទេ! អញថា «កុំទប់មុខដីធំ កុំទទឹងអាជ្ញា» ឥឡូវឃើញទេ! អាឯងអស់បានចូលមកកាន់ព្រះបរមរាជវាំងទៀតហើយ ។

កុមារជ័យ មិនអីទេលោក! ខ្ញុំទៅតែមួយពេលនេះទេ! ថ្ងៃស្អែកព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់នឹងមានព្រះបន្ទូលឲ្យខ្ញុំចូលមកវិញដដែល ។

កុមារជ័យ-សូមលោកអញ្ជើញចាំមើលទៅមើ! បើថាមិនមែន ។

ពួកអាមាត្យ-អើ! អញយកក្បិតជូនទល់ភ្នែកចាំមើលហើយថ្ងៃស្អែកនេះ ។

ចំណែកខាងព្រះមហាក្សត្រអង្គនេះ តែងមានតាបស ៤ អង្គចូលមកទទួលចង្ហាន់ជារាល់ព្រឹក មិនដែលដាច់ឡើយ ។

ព្រឹកឡើងកុមារជ័យមកអង្គុយសំកុកនៅក្បែរក្លោងទ្វារព្រះបរមរាជវាំង ។ មិនយូរប៉ុន្មានតាបសទាំង ៤ អង្គនោះនិមន្តមកដល់

កុមាជ័យមានទឹកភ្នែកហូរសស្រាក់ក្រាបថ្វាយបង្គំតាបសទាំង៤នោះ ហើយពោលថា ឱ! លោកម្ចាស់អើយ! ក្បាលលោកម្ចាស់រលីង ។ ដូចក្រប៉េះគូថខ្ញុំព្រះករុណា មិនគួរនឹងចូលព្រះបរមរាជវាំងបានសោះ, ត្រឡប់ជាចូលបាន ។ ក្បាលអាជ័យខ្ញុំព្រះករុណាសក់ញួរអង្គាជ ឡើងស្រគាំ ។ ដូចសក់សារិកាទៅជាអភ័ព្វចូលវាំងមិនបាន ។ នេះហៅចំជាបាបអាជ័យខ្ញុំព្រះករុណា បុណ្យក្បាលលោកម្ចាស់ ។

តាបសឮហើយទឹកខ្វល់ក្នុងចិត្តឥតចេញស្ដី ចូលទៅកាន់សំណាក់ព្រះមហាក្សត្រ ហើយក្រាបទូលថា បពិតមហារាជ! អាជ័យវាថាក្បាលអាត្មាភាពរលីង ។ ដូចក្រប៉េះគូថវាត្រឡប់ទៅជាចូលវាំងបាន ។

រឿងនេះអាត្មាភាពមិនសប្បាយចិត្តសោះ សូមមហារាជកាត់សេចក្ដីឲ្យអាត្មាភាពផង

មើល ៗ

ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់ពាក្យតាបសហើយ ទ្រង់ត្រាស់ឲ្យអាមាត្យទៅហៅកុមាជ័យចូលមកគាល់ ដើម្បីទ្រង់នឹងសួរហេតុភេទ ដោយផ្ទាល់ព្រះឱស្ឋ ៗ

អាមាត្យបានទៅហៅកុមាជ័យមកដល់ហើយ ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលសួរថា នែ! អាជ័យ! ហេតុអ្វីក៏អាឯងពោលប្រៀបធៀបប្រគេសតាបស ថាដូចជាក្រ-ប៉េះគូថអាឯង ៗ

កុមារជ័យ – សូមទ្រង់ព្រះមេត្តាប្រោស! ទូលព្រះបង្គំថាមែន តែទូលព្រះបង្គំមិនមែនថាដោយបន្តុះបង្អាប់លោកទេ គឺថាដោយសេចក្ដីសរសើរបុណ្យរបស់លោក ៗ

ព្រះមហាក្សត្រ – ចុះអាឯងពោលថាដូចម្ដេចខ្លះ បានជាថាពោលសរសើរទៅវិញ ៗ

កុមារជ័យ – ទូលព្រះបង្គំថាយ៉ាងនេះ៖

ឱ! លោកម្ចាស់អើយ! ក្បាលលោកម្ចាស់រលីង ៗ ដូចក្រប៉េះគូថខ្ញុំព្រះករុណា មិនគួរនឹងចូលព្រះបរមរាជវាំងបានសោះត្រឡប់ជាចូលបាន ៗ ក្បាលអាជ័យខ្ញុំព្រះករុណា មានសក់រួញអង្គាដីឡើងស្រគាំៗដូចសក់សារិកា ទៅជាអភ័ព្វចូលវាំងមិនបាន ៗ នេះហៅចំជាបាបក្បាលអាជ័យខ្ញុំព្រះករុណា បុណ្យក្បាលលោកម្ចាស់ ៗ (នៅមានត)

## ប្រវត្តិក្មេងកំព្រា (តបប់)

គេឃើញពិធីអាពាហ៍ពិពាហ៍មួយយ៉ាងឧឡារិកនៅគេហស្ថាននារីធន-សាវឿន ដែលធ្វើឡើងក្រោមការដឹកនាំនៃលោកដន្ទៅប្រសើរ ៗ គូស្វាមីភរិយានេះក៏បានរួមរក្សាសុខទុក្ខជាមួយគ្នាដោយសុវត្ថិភាពគ្មានហេតុអ្វីដែលនាំឲ្យផុលរមាស់ដល់ជីវភាពរបស់អ្នកទាំងពីរឡើយ, សេចក្ដីសុខនៃគ្រួសារថ្មីនេះជាដំណើរមួយដែលយើងគួរកត់សំគាល់បានថាជា

អំពើរកបានដោយកម្រ

១ខែ ៣ខែ ៦ខែ កន្លងផុតទៅ ហើយរាជរដ្ឋាភិបាលបានចាប់ផ្ដើមចាត់ការរៀបចំការរៀបរយក្នុងរដ្ឋដែលសព្វថ្ងៃនេះកំពុងតែមានមនុស្សច្រូលមកនាំបះបោរ ដោយដុំ ដោយអន្ទើរ ហើយដែរទាំងដើរប្លន់កាប់សម្លាប់អ្នកស្រុករឹបជាន់យកភោគសម្បត្តិរបស់ប្រជារាស្ត្រដែលជាអំពើយុងឃ្នងមួយ នាំសេចក្ដីក្ដៅក្រហាយដល់ប្រជាជនក្នុងស្រុកភូមិនិមួយ ៗ តាមពិតជនទុច្ចរិតនេះមិនមែនជាជនឯណាទេ គឺក្រុមរបស់នាយវិន្នានោះឯង ដែលតាំងពីនាយថយចេញផុតទៅ ក្រុមនោះក៏ក្លាយទៅជាពួកចោរដើររឹបជាន់ប្លន់យកភោគសម្បត្តិរបស់អ្នកស្រុកតែម្ដង ដែលមាននាយកួងជាមេដឹកនាំក្នុងក្រុមនោះ

រាជការបានចាត់កងរក្សាខែត្រ ជាច្រើននាក់ឲ្យទៅចាំឈ្លបស៊ើបការទឹងកំទេចពួកនេះចោល ៗ

ចំណែកនាយវិន្នាទឹងនាងនារីវិញ ដែលបានគៀសខ្លួនចេញផុតមកហើយ ក៏ខំលាក់ខ្លួនបំពួនអាត្មាធ្វើចំការដំណាំមួយនៅកោះទន្សាយ ដើម្បីទុកជារបរចិញ្ចឹមជីវិត ដោយចាំពេលទឹងមានឱកាសហុចឲ្យក៏ទឹងចូលខ្លួនមកសង្គមជាតិវិញ ៗ

ក្រុមរបស់នាយវិន្នាក៏ត្រូវគ្រោះថ្នាក់ជាខ្លាំង ដោយកងរាជការខែត្របេះតែដេញតាមប្រកិតជាប់ជានិច្ច មិនយូរប៉ុន្មានក៏ពួកនោះបានរត់មកជ្រកនៅលើកោះទន្សាយដែរ

កាលបើកងរក្សាខែត្របានដឹងច្បាស់ក្នុងរឿងនេះ ហើយគេក៏បានចាត់គ្នាមួយកងធំចូលហ៊ុំឡោមព័ទ្ធលើកោះនោះ មិនយូរប៉ុន្មានពួកចោរដែលមាននាយកួងជាមេក៏ត្រូវរាជការចាប់បានទាំងអស់គ្នា ចំណែកនាយវិន្នាទឹងនាងនារីសោតដោយខ្លួនបានមកពួនសម្ងំយកសុខនៅទីនេះដែរ ក៏ត្រូវគេចាប់ហើយចោទប្រកាន់ថា អ្នកបានចូលដៃផ្សំគំនិតជាមួយគ្នា ទុកបីឆ្លើយដោះដូចម្ដេចក៏ដោយ ក៏ត្រូវតែខ្លួនទទួលកំហុសនោះដែរ ដោយ

ហេតុថាខ្លួនធ្លាប់ជាមេនៃក្រុមនេះពីអតីតមកផង ហើយផ្នែករាជការក៏ពុំបានដឹងហេតុការខាងក្នុងនៃក្រុមនោះដែរ

ក្នុងការចាប់ក្រុមចោរនេះ រាជការបានយកខ្លួនទាំងអស់គ្នាទៅឃុំទុកនៅមន្ទីរពន្ធនាគារធំ ឯរាជធានីភ្នំពេញដើម្បីចាំស៊ើបសួរពិនិត្យរកហេតុការណ៍តទៅទៀត ៗ

នៅក្នុងគេហស្ថានរបស់លោកសំណាង គេឃើញមានការជ្រួលច្របល់ផ្ទុកឈ្មូតា ដោយមានក្រុមព្រះនគរបាលហ៊ុំព័ទ្ធជុំវិញ ហាក់ដូចជាខ្លាចមនុស្សក្នុងផ្ទះនេះរត់ចេញ ៗ ក្រោយនេះបន្តិចសំណាងក៏ត្រូវក្រុមព្រះនគរបាលនាំខ្លួនទៅ ដោយមិនដឹងជាមានហេតុអ្វីក្នុងដំណើរនេះ ទោះបីអ្នកស្រីធន - សារឿនប្រឹងអង្វរនឹងសួរយ៉ាងណាក៏ដោយ គេក៏មិនអាចទទួលស្ដាប់ពាក្យនោះបានឡើយ គេគ្រាន់តែឆ្លើយឡើងថា « កុំឲ្យគេចាប់នាងឯងយកទៅទៀតផងនោះក៏ជាការប្រសើរណាស់ទៅហើយ នាងដឹងដែរមនុស្សដែលមានចិត្តជាចោរហើយចូលមកបន្ទំរស់នៅជាមួយនឹងមនុស្សសុចរិត តើអនាគតនឹងបានឲ្យផលនាងរបៀបណាទៅវិញ ? »

អ្នកស្រីសំណាងហៅធន - សារឿន មានការងឿងឆ្ងល់នឹងសំដីនេះខ្លាំងណាស់ ដោយប្ដីខ្លួនមិនដែលប្រព្រឹត្តអំពើថោកទាបលាមកត្រង់ណាមួយសោះ តើពេលនោះម្ដេចក៏ក្លាយទៅជារបៀបនេះទៅវិញ នឹងជាបញ្ហាបែបណា នាងគិតមិនលេច

៦ ខែកន្លងមកទៀតហើយក៏ពុំឃើញបានលទ្ធផលអ្វីពីរឿងដែលសំណាងត្រូវចោទនោះសោះ គេគ្រាន់តែយកទៅឃុំទុកចោលប៉ុណ្ណោះ

ខែទី ៧ បានចូលមកដល់ហើយ ៗ នៅចំពោះមុខតុលាការគេឃើញមានសំណាងលោកជង្ហៅប្រសើរ អ្នកស្រីធន - សារឿន ភ្នាក់ងារគងរក្សាខែត្រ ៣រូប នាយវិន្ទា នាងនារីនឹងនាយក្លួង ដែលចាំឆ្លើយសំនួរបស់តុលាការ

តុលាការចាប់សួរលោកដង្កៅប្រសើរឲ្យរៀបរាប់ពីប្រវត្តិសំណាងតាំងតែពីដើមដល់ចុង ដែលមានទាក់ទងលើហេតុកេទដូចម្ដេចខ្លះ ?

សួរសំណាងពីរឿងនាយវិទ្នោកៀសខ្លួនបាត់

សួរអ្នកស្រីធន-សារឿនឲ្យរៀបរាប់តាមរឿងដែលខ្លួនបានជួបនឹងសំណាង

សួរគង់រក្សាខែត្រ ៣ នាក់ដែលបានទៅជួបក្នុងពេលជាមួយគ្នា

សួរនាយវិទ្នោដែលបានជួបសំណាង

សួរនាងនារីដែលរត់ទៅតាមនាយវិទ្នោ

ទីបំផុតសួរនាយកួង

បំណែកនាយកួងបានឆ្លើយហូរហែតាមរឿងទាំងអស់ តែខ្លួនដែលមានគំនុំខ្លះនឹងសំណាង ក៏បានឆ្លើយដាក់កំហុសរឿងចោរកម្មថាមានសំណាងជាអ្នកជួយផ្ដល់សម្ភារៈនឹងស្បៀងអាហារសត្វយានដល់ខ្លួន តែការឆ្លើយនេះគ្មានធ្វើជាភស្តុតាងមាំក្នុងរឿងចោរកម្មនោះទេ

វិនិច្ឆ័យសេចក្ដីចំពោះមុខ

ក្រោយពីតុលាការបានពិភាក្សាពិចារណារកហេតុខុសត្រូវហើយ ក៏បានវិនិច្ឆ័យដូចតទៅ

១. សំណាងមិនមានហេតុកេទអ្វីដែលគួរនឹងឲ្យតុលាការចោទប្រកាន់បានថាជាមនុស្សផ្សើគិតទន្ទឹងពពួកឡើយ តែត្រូវទទួលបង់អក័ព្វដោយមិនបានដម្ងឺចិត្តក្នុងរយៈពេលឃុំឃាំងគ្មានកំហុស ដោយតុលាការបានទម្លាក់ទោសនេះទៅលើនាយកួងវិញ

២- នាយវិទ្នោ ឲ្យសិទ្ធិនៅក្រៅការឃុំឃាំងតែត្រូវតុលាការព្យួរទោសទុកក្នុងរយៈពេល ៥ ឆ្នាំ បើមិនបះពានលើអំពីដូចធ្លាប់មានមកពីមុនទេ នោះនឹងត្រូវផុតការចោទ

ប្រគាន់របស់តុលាការពីពេលនោះទៅ

៣- នាយកួនត្រូវទទួលទោសលើខ្លួនទាំងស្រុង ដោយប្រព្រឹត្តអំពើចោរកម្មដើរសង្កត់សង្កិនបំផ្លាញអ្នកស្រុក ឲ្យពួកបនដោយមានអាវុធដើររិបជាន់យកសម្បត្តិប្រជាជនគ្រប់និគមជនបទ ត្រូវជាប់ពិរុទ្ធតុលាការជាបទឧក្រិដ្ឋទី១ ដាក់គុក២០ឆ្នាំ បង្ខំឲ្យធ្វើការគ្មានត្រាប្រណី ។

ក្នុងពេលដែលសំណាងបានរួចខ្លួនដូចដើមវិញហើយ អ្នកក៏បានពិចារណាតាមរឿងហេតុផ្ទាល់ខ្លួនអ្នកតាំងពីដើមរហូតដល់ចប់ ទីបំផុតអ្នកក៏ត្រូវលះបង់គេហស្ថាន ភោគសម្បត្តិ ភរិយានឹងបុត្រប្រុសមួយដែលទើបនឹងប្រសូត្របាន ៣ ខែ ។

អ្នកស្រីធន-សារឿនក៏មិនបានហាមឃាត់ ក្នុងដំណើរសាងកុសលរបស់ប្តីនាងឡើយ ទីបំផុតនាងក៏បានបំបួសប្តីរបស់នាងឲ្យបានជាភិក្ខុមួយរូបក្នុងព្រះពុទ្ធសាសនា ។

៦ ខែក្រោយមកទៀត គេក៏ឃើញអ្នកស្រីធន-សារឿន ស្លៀកសពាក់ស រក្សាសិក្ខាបទ ១០ ដូចជាសាមណេរីមួយរូបដែរ មុននឹងនាងលះបង់ដើម្បីសេចក្តីសុខសម្រាប់ជីវិតនាងទៅអនាគត អ្នកស្រីធន-សារឿន បានបំណាយសម្បត្តិទ្រព្យទាំងប៉ុន្មានឲ្យទៅជាទានអស់រយៈវេលា ៧ ថ្ងៃ នៅសល់ប៉ុន្មានក៏ប្រគល់ទាំងផ្ទះសំណល់នៃភោគទ្រព្យនឹងបុត្រប្រុសសំឡាញ់របស់នាងមួយឲ្យនាយវិន្ទោ និងនាងនារី ទទួលរក្សានិងចិញ្ចឹមបីបាច់តទៅ ។

សេចក្តីកង្វល់សព្វយ៉ាងនឹងវិនាសទៅបាន ក៏ដោយអាស្រ័យការលះបង់ ។

ចប់

ហ. ហ.

រោងពុម្ពវិរិយ

នៅខាងត្បូងផ្សារអូរឫស្សីសង្កាត់លេខ៥